# សៀវភៅណែនាំអំពីថវិកាជាតិ



## សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំអំពីថវិកាជាតិនេះ ផលិតដោយគម្រោងតាមដានថវិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការសហការពីវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ។ សៀវភៅណែនាំនេះទទួលបាននូវយោបល់ដ៏មានតម្លៃ ពីសំណាក់សមាជិករបស់បណ្តាញការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងអ្នកជំនាញផ្នែកខាងគ្រប់គ្រងហិរញ្ញវត្ថុមួយចំនួន ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ និងបុគ្គលទាំងអស់ដែលរួមចំណែកដល់ការបោះពុម្ពនេះ ។

# សៀវភៅណែនាំអំពីថវិកាជាតិ

ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៧

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល  ស្តីពីកម្ពុជា

សៀវភៅណែនាំអំពីថវិកាជាតិនេះ ផលិតឡើងរួមគ្នាដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការសហការពីវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងបោះពុម្ពផ្សាយ និងកែសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។ ខ្លឹមសារនៃឯកសារនេះអាចដកស្រង់និងផលិតឡើងវិញបាន ក្នុងគោលបំណង បម្រើដល់ការងារអភិវឌ្ឍន៍ ប៉ុន្តែសូមឱ្យមានការទទួលស្គាល់សិទ្ធិអ្នកបោះពុម្ពផ្សាយ ។

# មាតិកា


តារាង រូប និងប្រអប់ ..... iii

តារាងពាក្យបំព្រួញ ..... v

១. សេចក្តីផ្តើម ..... ១

២. ថវិកាជាតិ ..... ៣

២.១ តើថវិកាជាតិគឺជាអ្វី? ..... ៣

២.២ សារសំខាន់នៃថវិកាជាតិ ..... ៣

២.៣ រចនាសម្ព័ន្ធនៃថវិកាជាតិ ..... ៤

២.៣.១ ចំណូល ..... ៤

២.៣.២ ចំណាយ ..... ៥

២.៣.៣ ឱនភាព ..... ៦

២.៣.៤ ការបង្ហាញថវិកាជាតិ ..... ៧

២.៤ គោលបំណងនៃថវិកាជាតិកម្ពុជា: កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ..... ១០

៣. វដ្តថវិកា ..... ១១

៣.១ រៀបចំផែនការយុទ្ធសាស្ត្រ (ពីខែមីនា ដល់ខែឧសភា) ..... ១១

៣.២ រៀបចំថវិកា (ពីខែមិថុនា ដល់ខែកញ្ញា) ..... ១២

៣.៣ អនុម័តថវិកា (ពីខែតុលា ដល់ខែធ្នូ) ..... ១៣

៣.៤ ការអនុវត្ត ការតាមដាន និងការគ្រប់គ្រង (ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ) ..... ១៤

៣.៥ ការធ្វើសវនកម្មថវិកា ..... ១៦

៤. និន្នាការនៃថវិកាជាតិ ..... ១៧

៤.១ និន្នាការចំណូល ..... ១៨

៤.២ និន្នាការចំណាយ ..... ២២

៤.២.១ ចំណាយចរន្ត (ថវិកាអនុវត្ត) ..... ២៤

៤.២.២ ចំណាយមូលធន ..... ២៧

៤.៣ និន្នាការនៅក្នុងការសងការប្រាក់ និងការសងរំលស់បំណុល ..... ២៨

៤.៤ វិមជ្ឈការ និងថវិកា ..... ២៨

៤.៥ បំណុលសាធារណៈ ........ ៣០
៥. បញ្ហាដែលពាក់ព័ន្ធ ........ ៣៣
៥.១ ការទទួលព័តិមានពីថវិកា ........ ៣៣
៥.១.១ ឯកសារថវិកាដែលបានផ្សព្វផ្សាយជាសាធារណៈ ........ ៣៤
៥.១.២ ឯកសារថវិកាដែលមិនអាចរកបានជាសាធារណៈ ........ ៣៥
៥.២ ប្រភពចំណូលដែលកំពុងលេចឡើង ........ ៣៦
៥.២.១ ប្រេង និងឧស្ម័ន ........ ៣៦
៥.២.២ រ៉ែ ........ ៣៧
៥.២.៣ ការជំពាក់វាក់វីណ្ណនៃចំណូលពីឧស្សាហកម្មនិស្សារណៈកម្ម ........ ៣៧
ឧបសម្ព័ន្ធ ១: សទ្ទានុក្រម ........ ៣៩
ឧបសម្ព័ន្ធ ២: ឯកសារសម្រាប់អានបន្ថែម និងគេហទំព័រដែលពាក់ព័ន្ធ និងមានប្រយោជន៍ ........ ៤១
ឯកសារសម្រាប់អានបន្ថែម ........ ៤១
គេហទំព័រដែលពាក់ព័ន្ធ និងមានប្រយោជន៍ ........ ៤២
ឧបសម្ព័ន្ធ ៣: តារាងថវិកា ២០០៧ ........ ៤៧
ឧបសម្ព័ន្ធ ៤: តារាងចំណាយចរន្ត និងមូលធន ២000-២00៦ ........ ៥១
ឯកសារយោង ........ ៥៧

# តារាង រូប និងប្រអប់


តារាង ២.១ : រចនាសម្ព័ន្ធនៃថវិកាជាតិកម្ពុជា (ឆ្នាំ ២០០៧)...................................................... ៧
តារាង ២.២ : ការវិភាជន៍សម្រាប់ថវិកាផ្នែកលើកម្មវិធីសម្រាប់ក្រសួងអាទិភាពទាំងប្រាំពីរឆ្នាំ២០០៧. ៨
តារាង ៣.១ : ប្រតិទិនថ្មីសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំថវិកាជាតិ.......................... ១៤
តារាង ៤.១ : ចំណាយចរន្តពីឆ្នាំ ២០០០-២០០៦ ក្នុងចំណែកចំណាយចរន្តសរុប.......................... ២៥
តារាង ៤.២ : ចំណាយមូលធនពីឆ្នាំ ២០០០-២០០៦ ក្នុងចំណែកចំណាយមូលធនសរុប................. ២៧
តារាង ៤.៣ : និន្នាការនៅក្នុងការសងរំលស់បំណុល និងការប្រាក់ ២០០០-២០០៦...................... ២៨
តារាង ៤.៤ : បំណុលសាធារណៈដែលនៅមិនទាន់សង ឆ្នាំ ២០០៥ គិតជាលានរៀល .................. ៣០
តារាង A.៤.១ : និន្នាការថវិកា: ចំណាយចរន្ត ២០០០-២០០៦ គិតជាលានរៀល........................ ៥២
តារាង A.៤.២ : និន្នាការថវិកា: ចំណាយមូលធន ២០០០-២០០៦ គិតជាលានដុល្លារស.រ.អ ......... ៥៣
តារាង A.៤.៣ : និន្នាការថវិកា: ចំណាយចរន្ត ២០០០-២០០៦ គិតជាលានរៀល. ...................... ៥៤
តារាង A.៤.៤ : និន្នាការថវិកា: ចំណាយមូលធន ២០០០-២០០៦ គិតជាលានដុល្លារ ស.រ.អ ......... ៥៥

ច្បាប់ថវិកា ២០០៧ : តារាង ក (ចំណូល)................................................................................ ៤៧
ច្បាប់ថវិកា ២០០៧ : តារាង ខ (ចំណាយ)................................................................................ ៤៨
ច្បាប់ថវិកា ២០០៧ : តារាង គ (ចំណាយមូលធន) ............................................................ ៤៩

ប្រអប់ ២.១ : ការអធិប្បាយអំពីតារាងនានានៅក្នុងថវិកាជាតិ ................................................ ៩
ប្រអប់ ៤.១ : ការលំបាកដែលរដ្ឋាភិបាលប្រឈមមុខក្នុងការធ្វើវិភាជន៍ថវិកា........................... ១៧

រូបភាព ៣.១ : ដំណើរការនៃការអនុម័តច្បាប់ថវិកានៅក្នុងរដ្ឋសភា...................................... ១២
រូបភាព ៤.១ : ចំណែកនៃចំណូលឆ្នាំ ២០០៦.............................................................................. ១៩
រូបភាព ៤.២ : ចំណូលក្នុងស្រុក ពន្ធ មិនមែនពន្ធ និងមូលធន ២០០០-២០០៦ ......................... ២១
រូបភាព ៤.៣ : ចំណាយចរន្តតាមផ្នែក ២០០០-២០០៦.................................................... ២៣
រូបភាព ៤.៤ : ចំណែកនៃថវិកាមូលធន: វិស័យអាទិភាព និងវិស័យមិនអាទិភាព .......................២៦
រូបភាព ៥.១ : ចំណូលប្រេង និងឧស្ម័ន និងការអភិវឌ្ឍ...................................................... ៣៨

# តារាងពាក្យបំព្រួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| GDP | ផលិតផលសរុបក្នុងស្រុក |
| EITI | គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម |
| EI'S | ឧស្សាហកម្មនិស្សារណកម្ម |
| IDA | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PFMRP | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |

# ១ សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជាគឺជាស្ថាប័នហិរញ្ញវត្ថុដ៏ធំនិងស្មុគស្មាញមួយ ។រៀងរាល់ឆ្នាំរាជរដ្ឋាភិបាលកម្ពុជា ប្រមូល និងចាយប្រាក់រាប់រយលានដុល្លារ ។ ប្រាក់នេះគឺបានមកពីពន្ធអាករ ថ្លៃឈ្នួលនិងប្រាក់ពិន័យ ជំនួយបរទេស និងពីប្រភពផ្សេងៗទៀត ។ ប្រាក់នេះត្រូវបានចំណាយលើប្រតិបត្តិការរបស់រាជរដ្ឋាភិបាលៈ ឧទាហរណ៍ បើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល នៅតាមក្រសួង សាលារៀន មន្ទីរពេទ្យ និងប៉ុស្តិ៍នគរបាល និងវិនិយោគលើផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រពជាដើម ។ ជាសង្ខេបវិធីដែលប្រាក់នេះត្រូវបានប្រមូល និងវិធីដែលប្រាក់នេះត្រូវបានចាយ មានផលប៉ះពាល់ដល់មនុស្សគ្រប់គ្នានៅក្នុងប្រទេសកម្ពុជា ។

តើអ្នកណាជាអ្នកទទួលខុសត្រូវលើប្រាក់រាប់រយលានដុល្លារនេះ? ជាទីបំផុតយើងដែលជាពលរដ្ឋនៃប្រទេសកម្ពុជា គឺជាអ្នកទទួលខុសត្រូវ ។ ប្រជាពលរដ្ឋកម្ពុជាអនុវត្តការគ្រប់គ្រងដោយចូលរួមក្នុងការបោះឆ្នោត ។ រដ្ឋាភិបាលជាប់ឆ្នោតធ្វើសេចក្ដីសម្រេចចិត្តសំខាន់ៗក្នុងនាមយើងទាំងអស់គ្នា ។ ប៉ុន្តែក្រៅពីដំណើរការបោះឆ្នោត ការចូលរួមរបស់ពលរដ្ឋនៅក្នុងដំណើរការថវិកាប្រចាំឆ្នាំនាពេលបច្ចុប្បន្ន គឺនៅមានកម្រិត។ ការចូលរួមកាន់តែច្រើនឡើងនៅក្នុងដំណើរការថវិកា អាចនាំឱ្យមានការផ្សារភ្ជាប់ផ្ទាល់កាន់តែច្រើនឡើងរវាងចំណាយរដ្ឋាភិបាល និងការសម្រេចបាននូវសេចក្ដីត្រូវការ បំណងប្រាថ្នា និងការចង់បានរបស់ប្រជាពលរដ្ឋកម្ពុជា ។ វាក៏នឹងនាំឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅផងដែរអំពីលទ្ធិប្រជាធិបតេយ្យ និងតួនាទីដែលពលរដ្ឋកម្ពុជាអាចបំពេញដើម្បីធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាព ។

ចំណេះដឹងអំពីថវិកាជាតិ វដ្តថវិកា និងនិន្នាការនៃប្រាក់ចំណូលនិងចំណាយ គឺមានតែនៅជាមួយនឹងអ្នកឯកទេសមួយចំនួនតូចនៅក្នុងរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ស្ថាប័នស្រាវជ្រាវ និងនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍តែប៉ុណ្ណោះ។ ថ្វីបើមានច្បាប់ និងអត្ថបទបច្ចេកទេសជាច្រើនក្តី ក៏គេពុំឃើញមានប្រភពតែមួយដែលផ្តល់ព័ត៌មានពេញលេញអំពីថវិកានិងដំណើរការថវិកាឡើយ ។សៀវភៅណែនាំនេះមានបំណងបំពេញកង្វះខាតនេះ និងសំដៅ ធ្វើជាធនធានដ៏មានប្រយោជន៍មួយ សម្រាប់ជនគ្រប់រូបដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយថវិកាជាតិ រួមមានមន្ត្រីរាជរដ្ឋាភិបាល សមាជិករដ្ឋសភា អ្នកសារព័ត៌មាន សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងពលរដ្ឋកម្ពុជាទាំងអស់ ។ ដោយប្រើសៀវភៅណែនាំនេះ ភាគីពាក់ព័ន្ធទាំងអស់ ដែលបានលើកឡើងខាងលើនឹងអាចមានការយល់ដឹងអំពីដំណើរការថវិកា និងអាចរួមចំណែកផ្ទាល់ខ្លួនទៅក្នុងការពិភាក្សាអំពីថវិកាជាតិប្រកបដោយលក្ខណៈស្ថាបនា ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដូចតទៅៈ ជំពូក ២ កំណត់និយមន័យថវិកាជាតិ អធិប្បាយពីសារសំខាន់របស់វា និងផ្តល់ព័ត៌មានពិស្តារអំពីប្រភេទខុសៗគ្នានៃចំណូលនិងចំណាយ អំពីវិធីដែលច្បាប់ស្តីពីថវិកាជាតិ បង្ហាញព័ត៌មាននេះនៅក្នុងតារាងរបស់ច្បាប់នេះ និងបំណងប្រាថ្នាដែលរដ្ឋាភិបាលមានចំពោះថវិកាជាតិរបស់ខ្លួន ដូចមានលើកឡើងនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជំពូក៣ រៀបរាប់ពីដំណាក់កាលផ្សេងៗនៃវដ្តថវិកា ការកំណត់ពេលវេលា និងស្ថាប័ននានាដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ និងសកម្មភាពនានារបស់ស្ថាប័នទាំងនេះ ។ ជំពូក ៤ បង្ហាញទស្សនៈរួមអំពីនិន្នាការនៅក្នុងចំណូល និងចំណាយនៅក្នុងថវិកាជាតិពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦ ក៏ដូចជានិន្នាការនៅក្នុងការទូទាត់បង់ការប្រាក់ និងការសងរំលស់បំណុល នៅក្នុងរយៈពេលនេះដែរ ។ ជំពូក៤ បន្តជាមួយនឹងការវាយតម្លៃលើឥទ្ធិពលនៃថវិកាជាតិ លើការកាត់បន្ថយភាពក្រីក្រ និងផ្តល់នូវទស្សនៈរួមអំពីបញ្ហានានាទាក់ទិននឹងវិមជ្ឈការនិងវិសហមជ្ឈការ (D&D) ក៏ដូចជា បញ្ហានានា ទាក់ទិននឹងបំណុលសាធារណៈផងដែរ ។ ជំពូកចុងក្រោយនៃសៀវភៅណែនាំនេះ ពិនិត្យមើលបញ្ហាពាក់ព័ន្ធនានា ដូចជាលទ្ធភាពទទួលព័ត៌មានទាក់ទិននឹងថវិកា និងប្រាក់ចំណូលអនាគតដែលរំពឹងថា បានមកពីធនធានធម្មជាតិ ប្រេងកាត ឧស្ម័ន និង រ៉ែ ។

ឧបសម្ព័ន្ធ១ រួមមានបញ្ជីនៃការពន្យល់បច្ចេកស័ព្ទសំខាន់ៗដែលប្រើនៅក្នុងសៀវភៅណែនាំនេះ ។ ឧបសម្ព័ន្ធ២ ផ្តល់ទស្សនៈរួមអំពីឯកសារអាន និងគេហទំព័រអំពីថវិកាជាតិកម្ពុជា អំពីច្បាប់ពាក់ព័ន្ធ និងអំពីទិន្នន័យផ្សេងទៀត ក៏ដូចជាព័ត៌មានទូទៅស្តីពីហិរញ្ញវត្ថុសាធារណៈផងដែរ។ ឧបសម្ព័ន្ធ ៣ និង៤ រួមមានតារាង ដែលផ្តល់ទិន្នន័យពិស្តារអំពីនិន្នាការនៅក្នុងថវិកាជាតិពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦ ក៏ដូចជាតារាងដែលផ្តល់សេចក្តីដកស្រង់លម្អិតពីច្បាប់ស្តីពីថវិកាជាតិឆ្នាំ ២០០៧ សម្រាប់អ្នកដែលចង់បានភ្លាមៗនូវទិន្នន័យខ្លះដែលមាន។

សៀវភៅណែនាំនេះ គឺជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងដ៏ទូលំទូលាយមួយរបស់គម្រោងតាមដានថវិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាដែលប្រឹងប្រែងបង្កលក្ខណៈងាយស្រួលអោយមានកិច្ចពិភាក្សាប្រកបដោយការកែលំអ និងមានភស្តុតាងច្បាស់លាស់ រវាងអង្គការសង្គមស៊ីវិល និងអង្គការនីតិប្រតិបត្តិ និងអង្គការនីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។ រាល់មតិយោបល់លើសៀវភៅណែនាំនេះ ក៏ដូចជាការស្នើសុំផ្សេងៗ អាចផ្ញើជូនទៅគម្រោងតាមដានថវិកានៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមអាសយដ្ឋានដែលមាន នៅខាងចុងសៀវភៅណែនាំនេះ ។

# ២ ថវិកាជាតិ

## ២.១ តើថវិកាជាតិគឺជាអ្វី?

ថវិកាជាតិគឺជាសេចក្តីថ្លែងការណ៍មួយរបស់រដ្ឋាភិបាលស្តីពីគម្រោងប្រមូលចំណូលនិងការចំណាយ ។ ថវិកាជាតិអនុញ្ញាតឱ្យរដ្ឋាភិបាលកំណត់ថា តើខ្លួនមានប្រាក់ចំណូលគ្រប់គ្រាន់ឬទេ ដើម្បីបំពេញចំណាយរបស់ខ្លួន ។ ថវិកាជាតិផ្តល់អាជ្ញាឱ្យអង្គការនីតិប្រតិបត្តិប្រមូលចំណូល និងចំណាយទៅវិញ ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន ដូចជាការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច ។ ថវិកាជាឧបករណ៍ដ៏សំខាន់បំផុតរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយទាំងនេះ ។

នៅប្រទេសកម្ពុជាថវិកាជាតិត្រូវបានរៀបចំរៀងរាល់ឆ្នាំ សម្រាប់អនុវត្តនៅក្នុងឆ្នាំប្រតិទិនខាងមុខ (ដែលកើតឡើងស្របពេលគ្នាជាមួយនឹងឆ្នាំសារពើពន្ធ) ។ ថវិកាជាតិត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល និងចាំបាច់ត្រូវមានការយល់ព្រមដោយរដ្ឋសភា និងព្រឹទ្ធសភាមុនពេលអនុវត្ត ។ ក្រោយពេលបានទទួលការយល់ព្រមពីអង្គការនីតិប្បញ្ញត្តិរួចហើយ ថវិកាជាតិក្លាយទៅជាច្បាប់ ។

## ២.២ សារសំខាន់នៃថវិកាជាតិ

ការធ្វើថវិកាគឺជាផ្នែកដ៏សំខាន់បំផុតមួយនៃសង្គម ។ នៅក្នុងពិភពលោកដ៏រវល់ និងតឹងតែងសព្វថ្ងៃនេះ យើងធ្វើថវិកាលើពេលវេលារបស់យើង ចំណីអាហាររបស់យើង សម្លៀកបំពាក់របស់យើង និងការកំសាន្តរបស់យើង ។ល។ ក្នុងករណីដែលធនធានឬប្រាក់មានកម្រិត ការធ្វើថវិកាអាចជួយធានាឱ្យបានថា ប្រាក់ត្រូវបានចាយប្រកបដោយប្រសិទ្ធភាព ។ ដោយប្រើថវិកាយើងអាចដឹងជាមុនថា តើប្រាក់ចំណូលប៉ុន្មានយើងនឹងអាចទទួលបាន និងថាតើយើងអាចចាយប្រាក់ប៉ុន្មានលើអាទិភាពជាក់លាក់មួយចំនួននៅក្នុងរយៈពេលជាក់លាក់មួយ ។

ដូចគ្នានេះដែរ រាជរដ្ឋាភិបាលប្រើថវិកាជាតិជាឧបករណ៍ធ្វើផែនការមួយសម្រាប់កៀងគរចំណូល និង ដើម្បីកំណត់ចំណាយដើម្បីបំពេញសេចក្តីត្រូវការលើផ្នែកអភិវឌ្ឍ ។ ថវិកាដែលរៀបចំបានល្អមួយពោលគឺថវិកា ដែលឆ្លុះបញ្ចាំងអាទិភាពគោលនយោបាយសង្គម សេដ្ឋកិច្ចរបស់ប្រទេស និងអនុញ្ញាតឱ្យរដ្ឋាភិបាលអាចសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍របស់ខ្លួន ។

ជាសង្ខេប ថវិការបស់ប្រទេសមួយមានឥទ្ធិពលលើជីវភាពប្រចាំថ្ងៃ និងអនាគតរបស់សង្គមទាំងមូល ។ សេចក្ដីសម្រេចចិត្តអំពីការធ្វើថវិកា មានផលប៉ះពាល់លើគ្រប់សកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ច តាំងពីទីកន្លែងដែលយើងរស់នៅទីកន្លែងដែលយើងធ្វើការងារ មធ្យោបាយធ្វើដំណើរដែលយើងប្រើ ការថែទាំសុខភាព និងការអប់រំដែលយើងអាចទទួលបាន និងសុវត្ថិភាព អនាម័យ និងសេវាចាំបាច់នានាដែលយើងអាចទទួល ។

## ២.៣ រចនាសម្ព័ន្ធនៃថវិកាជាតិ

នៅប្រទេសកម្ពុជាថវិកាជាតិកម្ពុជាត្រូវបានរៀបចំសម្រាប់ប្រតិបត្តិការរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ ។ ច្បាប់ស្ដីពីថវិកាជាតិមានបីផ្នែកសំខាន់ៗគឺៈ

- ចំណូល
- ចំណាយ និង
- ឱនភាព

### ២.៣.១ ចំណូល

រដ្ឋាភិបាលរកចំណូលបានពីប្រភពផ្សេងៗ ដើម្បីធ្វើហិរញ្ញប្បទានលើសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍នានារបស់ខ្លួន ។ ចំណូលទាំងនេះត្រូវបានចែកចេញជាចំណូលចរន្តនិងចំណូលមូលធន។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាល បានប្ដេជ្ញាប្រមូលចំណូលក្នុងស្រុកឱ្យបានចំនួនសរុប ៣.២៨២.១៧៣ លានរៀល (៧៩៧,៦ លានដុល្លារ ស.រ.អ) ដែលនៅក្នុងនោះចំណូលចរន្តមានចំនួន ៣.២៥២.១៧៣ លានរៀល (៧៩០,៣ លានដុល្លារ ស.រ.អ) និងចំណូលមូលធនចំនួន ៣០.០០០ លានរៀល (៧,២ លានដុល្លារ ស.រ.អ)។

ចំណូលពន្ធនិងចំណូលមិនមែនពន្ធ គឺជាចំណូលចរន្ត ។ចំណូលពន្ធគឺជាចំណូលនានាដែលទទួលបានពីការយកពន្ធលើទំនិញ សេវា និងពាណិជ្ជកម្មអន្តរជាតិ ។ ឧទាហរណ៍នានា រួមមានពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន ពន្ធលើប្រាក់ចំណេញ ពន្ធអាករលើកាស៊ីណូ ពន្ធលើអចលនទ្រព្យ ពន្ធគយ ពន្ធតម្លៃបន្ថែម និងពន្ធលើការនាំឈើចេញ។ នៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៧ រាជរដ្ឋាភិបាលមានបំណងប្រមូលចំណូលពន្ធឱ្យបានចំនួនសរុប ២.៦៨២.០០០ លានរៀល (៦៥១,៧ លានដុល្លារ ស.រ.អ)។ គោលដៅចំណូលមិនមែនពន្ធសម្រាប់ឆ្នាំ ២០០៧ គឺ ៥៧០.១៧៣ លានរៀល (១៣៨,៥ លានដុល្លារ ស.រ.អ)។ ចំណូលនេះរួមមានចំណូលពីការជួល និងការលក់អចលនទ្រព្យ សាធារណៈ សម្បទានរ៉ែ សហគ្រាសសាធារណៈ ប្រាក់ចំណេញ ឯកជនភាវូបនីយកម្ម ថ្លៃលិខិតឆ្លងដែន និងទិដ្ឋាការ និងសេវារដ្ឋបាល។

ចំណូលមូលធនរួមមានចំណូលមូលធនក្នុងស្រុក ដែលភាគច្រើនបានមកពីវិនិយោគហិរញ្ញវត្ថុ និងចំណូលមូលធនពីប្រភពក្រៅប្រទេស ដែលរួមមានមូលនិធិទ្រទ្រង់ថវិកា ប្រាក់កម្ចី និងជំនួយឥត

សំណង[១] ។ ក្នុងឆ្នាំ ២០០៧ ផែនការចំណូលមូលធនសរុបគឺ ១.៣៧០.១៣៣ លានរៀល ( ៣៣៣ លានដុល្លារ ស.រ.អ) ដែលនៅក្នុង នោះ មានតែ ២,២ ភាគរយ ឬ ៣០.០០០ លានរៀល ( ៧,២ លានដុល្លារ ស.រ.អ) ប៉ុណ្ណោះគឺជាចំណូលមូលធនក្នុងស្រុក ។ ប្រាក់នៅសល់គឺជាប្រាក់កម្ចី និងជំនួយឥតសំណង ពីដៃគូអភិវឌ្ឍន៍ទ្វេភាគីឬពហុភាគី ។

ប្រៀបធៀបជាមួយប្រទេសមានប្រាក់ចំណូលទាបផ្សេងទៀត ចំណូលដែលប្រមូលបានដោយរដ្ឋាភិបាលកម្ពុជា គឺទាបណាស់ ដោយមានកម្រិតមធ្យមត្រឹមតែ ៦,៨ ភាគរយនៃផលិតផលក្នុងស្រុកសរុប (GDP) ប៉ុណ្ណោះ នៅក្នុងរយៈពេលពីឆ្នាំ ១៩៩៥ ដល់ ឆ្នាំ ២០០៤ (ចំណូលជាមធ្យមនៃប្រទេសមានប្រាក់ចំណូលទាបក្នុងរយៈពេលនេះមានចំនួន ១៤,២ ភាគរយ) (ធនាគារពិភពលោក ឆ្នាំ ២០០៧: ១៥៨) ។ ទោះជាយ៉ាងណាក្តី ដោយសារ មានកំណែទម្រង់ជាច្រើនដែលបានធ្វើឡើង ដើម្បីបង្កើនការប្រមូលប្រាក់ចំណូលចំនួននេះបានកើនឡើងដល់ ១០,៤ ភាគរយនៅក្នុងឆ្នាំ ២០០៦ (មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ ២០០៧)។ លើសពីនេះទៀត គោលបំណងមួយនៃគោលបំណងចម្បងទាំងឡាយ ដែលបានរៀបរាប់នៅក្នុងសារាចរមួយចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺថារាជរដ្ឋាភិបាលបានប្តេជ្ញាប្រមូលចំណូលឱ្យបានដល់ ១០,៩២ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០០៧។ វិធានការជាច្រើនកំពុងត្រូវបានបង្កើតឡើងដើម្បីប្រតិបត្តិការប្រមូលចំណូល ដែលភាគច្រើនពាក់ព័ន្ធនឹងទីចាត់ការគយ និងរដ្ឋាករក្នុងការប្រមូលចំណូលពន្ធ និងការប្រមូលចំណូលមិនមែនពន្ធដោយស្ថាប័នផ្សេងទៀត ។ ព័ត៌មានពិស្តារអំពីចំណូលរដ្ឋាភិបាល អាចរកឃើញនៅក្នុងតារាង ក នៃឧបសម្ព័ន្ធ ៣ (ចំណូលទូទៅរបស់រដ្ឋាភិបាលនៃច្បាប់ថវិកាជាតិ)។

## ២.៣.២ ចំណាយ

ចំណាយរបស់រដ្ឋាភិបាលត្រូវបានចែកចេញជាចំណាយចរន្ត និងចំណាយមូលធន ។ ក្នុងឆ្នាំ ២០០៧ ចំណាយសរុបរបស់រដ្ឋាភិបាលត្រូវបានគ្រោងក្នុងកម្រិត ៤.៥២២.៣០៦ លានរៀល (១.០៩៩ លានដុល្លារ ស.រ.អ) (មើលតារាង ២.១)។

ចំណាយចរន្តគឺជាមូលនិធិទាំងឡាយដែលប្រើដើម្បីរក្សាឱ្យសេវាកម្មដំណើរការរៀងរាល់ថ្ងៃ ។ ចំណាយ នេះរួមមានប្រាក់បៀវត្សរបស់មន្ត្រីរាជការ ទំនិញដែលចាំបាច់សម្រាប់ផ្តល់សេវាកម្ម (ដូចជាថ្នាំពេទ្យ និងសៀវភៅសិក្សា) និងសេវាកម្មផ្សេងៗទៀត ។ ឧទាហរណ៍ផ្សេងទៀតនៃចំណាយចរន្ត រួមមានអន្តរាគមន៍ផ្នែកសង្គមកិច្ច ឬសេដ្ឋកិច្ច ការទូទាត់បង់ការប្រាក់ និងចំណាយមិនមានការគ្រោងទុកជាមុនផ្សេងៗទៀត។ ចំណាយចរន្តក្នុងឆ្នាំ ២០០៧ ត្រូវបានគ្រោងក្នុងកម្រិត ២.៨៣៧.១៧៣ លានរៀល (៦៨៩,៤ លានដុល្លារ ស.រ.អ) ដែលបង្ហាញកំណើនជានាម ១៧,៥ ភាគរយ ប្រៀបធៀបជាមួយនឹងផែនការថវិកាឆ្នាំ ២០០៦។

ចំណាយមូលធន រួមមានវិនិយោគសម្រាប់អត្ថប្រយោជន៍អនាគត ការធ្វើហិរញ្ញប្បទានលើគម្រោង

*[១] មាត្រា៧ នៃច្បាប់ថវិកាឆ្នាំ២០០៧ ។ មុនឆ្នាំ២០០៧ ចំណូលមូលធនរួមមានចំណូលពីការលក់អចលនទ្រព្យ/ទ្រព្យសាធារណៈ និង ឯកជនភាវូបនីយកម្ម។ ប៉ុន្តែ ក្នុងច្បាប់ថវិកាឆ្នាំ២០០៧ ចំណូលទាំងនេះត្រូវបានចាត់ទុកជាចំណូលចរន្ត។*

វិនិយោគ មូលនិធិភាពជាដៃគូ និងការសងរំលស់បំណុល ។ ឧទាហរណ៍នៃចំណាយមូលធន រួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវថ្នល់ ស្ពាន បណ្តាញខ្សែអគ្គិសនី និងទូរគមនាគមន៍ ។ នៅក្នុងថវិកាជាតិកម្ពុជា ការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងនេះត្រូវរាប់បញ្ចូលនៅក្នុងថវិកាមូលធន ។ ច្បាប់ថវិកាឆ្នាំ២០០៧ វិភាជន៍ប្រាក់ចំនួន ១.៦៨៥.១៣៣ លានរៀល (៤០៩,៥ លានដុល្លារ ស.រ.អ) សម្រាប់ចំណាយមូលធន ដែលគឺជាកំណើនជានាម ២០,៤ ភាគរយ ប្រៀបធៀបជាមួយឆ្នាំ ២០០៦ ។

## ២.៣.៣ ឱនភាព

ឱនភាពបង្ហាញភាពខុសគ្នារវាងចំណូលក្នុងស្រុករបស់រដ្ឋាភិបាល (មិនរាប់បញ្ចូលជំនួយឥតសំណង់ និងប្រាក់កម្ចី)[២] និងចំណាយសរុប ។ ប្រសិនបើរដ្ឋាភិបាលមានចំណូលច្រើនជាងចំណាយ នោះគឺជាអតិរេក ។ ផ្ទុយទៅវិញប្រសិនបើរដ្ឋាភិបាលចាយច្រើនជាងខ្លួនប្រមូលបាន នោះនឹងមានឱនភាព។ នៅប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ស្ថានភាពចុងក្រោយនេះហើយគឺជាការពិត រាជរដ្ឋាភិបាលចាំបាច់ត្រូវខ្ចីប្រាក់ពីទីផ្សារមូលធនក្នុងស្រុក ឬអន្តរជាតិ ដើម្បីបំពេញឱនភាពនេះ។ ឱនភាពកម្ពុជាត្រូវបានផ្តល់ហិរញ្ញប្បទានភាគច្រើន ដោយដៃគូអភិវឌ្ឍន៍ ក្នុងទម្រង់ជាជំនួយឥតសំណងនិងប្រាក់កម្ចី។ ដូចមានបង្ហាញជូននៅក្នុងតារាង ២.១ ខាងក្រោមសម្រាប់ឆ្នាំ២០០៧ រាជរដ្ឋាភិបាលរំពឹងថានឹងប្រមូលចំណូលចរន្តបានច្រើនជាងចំណាយចរន្តរំពឹងបន្តិច ដែលនាំឱ្យមានអតិរេកថវិកាចរន្តចំនួន ៤១៥.០០០ លានរៀល (១០០,៨ លានដុល្លារ ស.រ.អ) ។ ប៉ុន្តែ ដោយរាប់បញ្ចូលថវិកាមូលធន ប្រទេសកម្ពុជានឹងមានឱនភាពចំនួន ១.២៤០.១៣៣ លានរៀល (៣០១,៣ លានដុល្លារ ស.រ.អ) ។ ឱនភាពនេះកំពុងត្រូវបានផ្តល់ហិរញ្ញប្បទានដោយប្រភពខាងក្រៅភាគច្រើនគឺដៃគូអភិវឌ្ឍន៍ ទាំងទ្វេភាគី និងពហុភាគី នៅក្នុងទម្រង់ជាប្រាក់កម្ចីនិងជំនួយឥតសំណង ។

នៅពេលណាដែលហិរញ្ញប្បទានមានទម្រង់ជាប្រាក់កម្ចីរដ្ឋាភិបាលត្រូវបង់ការប្រាក់ ក៏ដូចជាការសងបំណុលនាអនាគត ។ ការទូទាត់នេះគឺជាកាតព្វកិច្ចតាមកិច្ចសន្យា ។ ប្រការនេះមានន័យថារដ្ឋាភិបាលត្រូវតែចាត់ចែងសងការប្រាក់លើបំណុលរបស់ខ្លួន និងសងរំលស់បំណុល មុនពេលខ្លួនធ្វើថវិកាសម្រាប់មុខចំណាយដទៃទៀត ។ វាក៏មានន័យផងដែរថា នៅក្នុងពេលមួយនាអនាគតកាល គេត្រូវតែសងប្រាក់បំណុលផងដែរ គឺមិនមែនតែការប្រាក់ប៉ុណ្ណោះទេ ។

[២] *នៅក្នុងច្បាប់ថវិកា ជំនួយឥតសំណង និង ប្រាក់កម្ចី ត្រូវបានចាត់ទុកជាចំណូលមូលធនពីដៃគូអភិវឌ្ឍន៍ទ្វេភាគីឬពហុភាគី ។*

**តារាង ២.១: រចនាសម្ព័ន្ធនៃថវិកាជាតិកម្ពុជា (ឆ្នាំ ២០០៧)**

| ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ | ចំនួន | អតិរេក (+), ឱនភាព (-) |
|---|---|---|
| **I. ចំណូលក្នុងស្រុក** | ៣.២៨២.១៧៣ | |
| ១. ចំណូលចរន្ត | ៣.២៥២.១៧៣ | |
| ២. ចំណូលមូលធនក្នុងស្រុក | ៣០.០០០ | |
| **II. ចំណាយសរុប** | ៤.៥២២.៣០៦ | |
| ១. ចំណាយចរន្ត | ២.៨៣៧.១៧៣ | |
| ២. ចំណាយមូលធន | ១.៦៨៥.១៣៣ | |
| ▪ វិនិយោគសាធារណៈដែលទទួលហិរញ្ញប្បទានក្នុងស្រុក | ៥៧៥.១៣៣ | |
| • ថវិកាដែលបានទទួលមូលនិធិ | ៣៤៥.០០០ | |
| - គម្រោងវិនិយោគ | ២២០.០០០ | |
| - មូលនិធិដៃគូ | ១២៥.០០០ | |
| • វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា | ២៣០.១៣៣ | |
| ▪ វិនិយោគសាធារណៈដែលទទួលហិរញ្ញប្បទានខាងក្រៅ | ១.១១០.០០០ | |
| អតិរេកនៃថវិកាចរន្ត (I.១ – II.២) | | ៤១៥.០០០ |
| ឱនភាពនៃថវិកាទូទៅ (I-II) | | (១.២៤០.១៣៣) |
| **III. ហិរញ្ញប្បទាន** | | ១.២៤០.១៣៣ |
| ១. ហិរញ្ញប្បទានខាងក្រៅ | | |
| ▪ មូលនិធិទ្រទ្រង់ថវិកា | | ២៣០.១៣៣ |
| ▪ មូលនិធិវិនិយោគសាធារណៈខាងក្រៅដោយផ្ទាល់ | | ១.១១០.០០០ |
| ▪ ការសងបំណុល | | (១០០.០០០) |
| ២. ហិរញ្ញប្បទានក្នុងស្រុក | | |
| ▪ ហិរញ្ញប្បទានដោយធនាគារជាតិ | | |

ប្រភព: *ច្បាប់ថវិកាជាតិ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧)* ។

## ២.៣.៤ ការបង្ហាញថវិកាជាតិ

ចំណុចសំខាន់មួយនៃថវិកាជាតិកម្ពុជាវាមានលក្ខណៈទ្វេ ។ ប្រការនេះមានន័យថាចំណាយចរន្ត និងចំណាយមូលធនត្រូវបានបង្ហាញដោយឡែកពីគ្នា ដូចមានចែងនៅក្នុងសេចក្តីអធិប្បាយនៃតារាងផ្សេងៗនៅក្នុងច្បាប់ថវិកា ។ នៅក្នុងច្បាប់ថវិកាឆ្នាំ២០០៧ ជំហានទីមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការបង្ហាញថវិកាជាតិ ជាពិសេសការសាកល្បងរៀបចំថវិកាផ្នែកលើកម្មវិធីត្រូវបានចាប់ផ្តើម ។

កម្មវិធីត្រូវបានរៀបចំឡើងជាសកម្មភាពមួយចំនួន ដែលសំដៅរួមចំណែកដល់គោលដៅរដ្ឋាភិបាល ដែលអាចកំណត់បាន និងដែលបានកំណត់ថា តើអ្វីទៅគឺជាលទ្ធផលរំពឹង និងថាតើលទ្ធផលទាំងនេះ អាចវាយតម្លៃយ៉ាងដូចម្តេច ។

សម្រាប់ឆ្នាំ ២០០៧ ការសាកល្បងនេះ គឺផ្អែកលើការអនុវត្តកម្មវិធីសកម្មភាពអាទិភាព (PAP) ដែលចាប់ផ្តើមជាមួយក្រសួងអាទិភាពទាំងប្រាំពីរ ។ មូលនិធិសម្រាប់ការរៀបចំថវិកាផ្អែកលើកម្មវិធី សម្រាប់ឆ្នាំ ២០០៧ ត្រូវបានធ្វើគ្រោងក្នុងកម្រិត ៣៩៦.២២៥ លានរៀល (៩៦.២ លានដុល្លារ ស.រ.អ) ឬប្រហែល ១៤ ភាគរយនៃថវិកាសរុបបច្ចុប្បន្ន ។ ទឹកប្រាក់ទាំងអស់នេះត្រូវបានបែងចែកនៅក្នុងចំណោមក្រសួងអាទិភាពទាំងប្រាំពីរ និងតំណាងឱ្យទឹកប្រាក់ដ៏តិចតួចប៉ុណ្ណោះនៃថវិកាសរុបរបស់ក្រសួងនីមួយៗ ដើម្បីបំពេញកម្មវិធីអាទិភាពមួយចំនួនរបស់ខ្លួន។ ថ្វីបើកម្មវិធីដោយឡែកទាំងឡាយ មិនត្រូវបានដាក់បញ្ចូលនៅក្នុងតារាងនានានៃច្បាប់ថវិកា ឆ្នាំ ២០០៧ ក្តី ក៏ទស្សនៈរួមមួយនៃទឹកប្រាក់ពាក់ព័ន្ធនេះត្រូវបានផ្តល់ជូនដែរ ដូចមានបង្ហាញជូននៅក្នុងតារាង ២.២ ខាងក្រោមនេះ ។

**តារាង ២.២: ការវិភាជន៍សម្រាប់ថវិកាផ្អែកលើកម្មវិធីសម្រាប់ក្រសួងអាទិភាពទាំងប្រាំពីរ ឆ្នាំ២០០៧**

| | ចំនួនជាប្រាក់រៀល (លាន) | ចំនួនជាប្រាក់ដុល្លារ ស.រ.អ (លាន) | ចំណែកនៃ ចំណាយចរន្ត (%) |
|---|---|---|---|
| ក្រសួងអប់រំ | ១២៥.៩៤៧ | ៣០.៨ | ២៣.១ |
| ក្រសួងសុខាភិបាល | ៨២.៩៨៧ | ២០.២ | ២៤.៥ |
| ក្រសួងកសិកម្ម | ២៩.៦៣២ | ៧.៣ | ១៨.៧ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១៦. ២៩០ | ៤.០ | ៤៣.៧ |
| ក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម | ២.២០០ | ០.៥ | ១៣.៧ |
| ក្រសួងយុត្តិធម៌ | ១.២១០ | ០.៣ | ៦.៤ |
| ក្រសួងកិច្ចការនារី | ៨៦០ | ០.២ | ៥.២ |

**ប្រភព:** *"បរិបទនៃសេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០០៧" (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ ២០០៦ខ)*

ឧបសម្ព័ន្ធ២នៃសៀវភៅណែនាំនេះផ្តល់ជូនសេចក្តីដកស្រង់ពិស្តារមួយពីតារាងខ្លះៗនៃតារាងនានាពីច្បាប់ថវិកាឆ្នាំ ២០០៧ ។ ប្រអប់ ២.១ ផ្តល់នូវការអធិប្បាយអំពីតារាងទាំងប្រាំមួយដែលមាននៅក្នុងច្បាប់ថវិកាជាតិ ។ តារាង ក ផ្តល់ព័ត៌មានពិស្តារអំពីចំណូលរដ្ឋ ។ តារាង ខ ផ្តល់នូវទស្សនៈរួមអំពីចំណាយចរន្ត ។ តារាង គ១ គ២ និង គ៣ ពិនិត្យមើលចំណាយមូលធន ហើយតារាង ឃ បង្ហាញការវិភាជន៍ចំណាយមូលធនរវាង រដ្ឋបាលកណ្តាលនិងរដ្ឋបាលខេត្ត-ក្រុង ។

## ប្រអប់ ២.១: ការអធិប្បាយអំពីតារាងនានានៅក្នុងថវិកាជាតិ

- តារាង ក រៀបរាប់លម្អិតនូវចំណូលរដ្ឋ ។ តារាងនេះបង្ហាញចំណូលថវិកាសរុប (ទាំងចំណូលចរន្ត និងមូលធន ក៏ដូចជាចំណូលពីប្រភពក្នុងស្រុក និងក្រៅប្រទេសផងដែរ) ។ តារាងនេះដាក់បញ្ចូលចំណូលរំពឹង តាមខ្ទង់ ជំពូក គណនី និងគណនីរង ។ តួលេខត្រូវបានបង្ហាញជូនគិតជាលានរៀល ។ នៅក្នុងច្បាប់ថវិកា ឆ្នាំ២០០៧ តារាង ក រួមមានបួនទំព័រ ។

- តារាង ខ រៀបរាប់ពីចំណាយទូទៅរបស់រដ្ឋ ។ នៅក្នុងតារាងនេះ (បីទំព័រ) ចំនួនថវិកា ទាំងចរន្ត និងមូលធន ត្រូវបានធ្វើចំណាត់ថ្នាក់តាមប្រភេទ និងដាច់ដោយឡែកតាមក្រសួង ក្នុងកម្រិតសរុបរបស់រដ្ឋបាលកណ្តាល និងរដ្ឋបាលខេត្ត-ក្រុង ។ គេគប្បីកត់សម្គាល់ថា តារាងនេះផ្តល់តែព័ត៌មានអំពីចំណាយចរន្តប៉ុណ្ណោះ រីឯខ្ទង់សម្រាប់ចំណាយមូលធនគឺនៅចំហ ។

- តារាង គ១ និងគ២ រៀបរាប់លម្អិតនូវចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ។ តារាងទាំងនេះរាយបញ្ជីគម្រោងទាំងអស់សម្រាប់ក្រសួងខុសៗគ្នា ។ គម្រោងទាំងអស់ត្រូវបានរាយបញ្ជីតាមលេខគម្រោង ហើយថវិកាសម្រាប់គម្រោងនីមួយៗត្រូវបានបង្ហាញសម្រាប់រយៈពេលបីឆ្នាំខាងមុខ ។ ដោយសារតារាងនេះ ផ្តល់តួលេខថវិកាលម្អិតសម្រាប់គ្រប់គម្រោងវិនិយោគទាំងអស់វាមាន ១៤ ទំព័រ ។ តារាង គ១ បង្ហាញតួលេខជាពាន់ដុល្លារ ស.រ.អ ហើយតារាងគ២ ផ្តល់តួលេខជាលានរៀល ។

- តារាង គ៣ មានចំណងជើងថាចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ឥណទានកម្មវិធី[៣] និងឥណទានសន្យា ។ តារាងនេះគឺជាសេចក្តីសង្ខេបមួយទំព័រនៃវិនិយោគមូលធនគិតជាប្រាក់រៀល (លាន) សម្រាប់ក្រសួងនីមួយៗ ។ តារាងនេះក៏បង្ហាញផងដែរនូវឥណទានសន្យា ដែលគឺជាការរំពឹងវិនិយោគមូលធនដោយម្ចាស់ជំនួយ ។ ថវិកាឥណទានសន្យានេះគឺចែកចេញជាបីប្រភេទផ្សេងៗគ្នា: ១) កំពុងដំណើរការ ២) បានព្រមព្រៀងគ្នា និង ៣) ស្ថិតក្នុងការចរចាគ្នា ។

- តារាង ឃ អធិប្បាយពីចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ឥណទានសន្យា[៤] និងឥណទានទូទាត់ ។ តារាងនេះបង្ហាញតួលេខសម្រាប់ចំណាយមូលធនក្នុងកម្រិតសរុបជាប្រាក់រៀល (លាន) ។ ជួរបញ្ឈរនៃតារាងនេះបំបែកថវិកាតាមក្រសួង និងចែកថវិកានេះទៅតាមរដ្ឋបាលកណ្តាល និងរដ្ឋបាលខេត្ត-ក្រុង ។ ជួរផ្តេកនៃតារាងនេះបង្ហាញថវិកាសម្រាប់វិនិយោគសាធារណៈដែលបែងចែកតាមប្រភពផ្តល់មូលនិធិហិរញ្ញប្បទានក្នុងស្រុក និងហិរញ្ញប្បទានខាងក្រៅ ហើយត្រូវបានបំបែកបន្ថែមទៀតទៅតាមឥណទានសន្យា និងឥណទានទូទាត់ ។ នៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៧ តារាងឃ គឺមានបីទំព័រ ។

---

[៣] *ឥណទានកម្មវិធីគឺជាថវិកាសរុបសម្រាប់វិនិយោគមូលធន (ដែលផ្តល់មូលនិធិដោយប្រភពក្នុងស្រុកផង និងប្រភពក្រៅប្រទេសផង) ។ ឥណទានសន្យាគឺជាថវិកាដែលស្នើឡើងសម្រាប់ការផ្តល់មូលនិធិក្រៅប្រទេសពីម្ចាស់ជំនួយ ។ ជាធម្មតា ឥណទានសន្យានេះគឺនៅក្រៅថវិកា ក្នុងប្រតិបត្តិការ ។*

[៤] *កម្មវិធីវិនិយោគដែលស្នើឡើងទាំងអស់ (ឥណទានសន្យា) មិនសុទ្ធតែត្រូវបានរំពឹងថា ត្រូវបានយល់ព្រមទាំងអស់ទេ ។ ឥណទានទូទាត់ គឺជាថវិកាដែលរំពឹងថាត្រូវបានយល់ព្រមដោយម្ចាស់ជំនួយ ។*

## ២.៤ គោលបំណងនៃថវិកាជាតិកម្ពុជា: កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នៅក្នុងអារម្ភកថានៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានចាប់ផ្តើមក្នុងឆ្នាំ ២០០៥ នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា: "ជាចុងក្រោយបំផុត ការកៀរគរ ការគ្រប់គ្រង និងការវិភាជន៍ធនធានសាធារណៈ គប្បីទទួលបាននូវលទ្ធផលប្រសើរបំផុត សម្រាប់ឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋទាំងមូល ជាពិសេសសម្រាប់ជនដែលក្រីក្រ និងងាយរងគ្រោះ" និងគូសបញ្ជាក់សារសំខាន់នៃថវិកាជាតិ សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ។ នៅលើមាគ៌ាឆ្ពោះទៅកាន់ការបញ្ចប់ក្នុងឆ្នាំ ២០១៥ គោលបំណងនៃកម្មវិធីកំណែទម្រង់នេះ គឺដើម្បីសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលនឹងឈានដល់ស្តង់ដារខ្ពស់បំផុតទាំងនៅក្នុងតំបន់ និងអន្តរជាតិ ។ ដើម្បីសម្រេចបានគោលដៅនេះ សកម្មភាពនានាដែលអនុវត្តដោយរាជរដ្ឋាភិបាល នៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានការខិតខំឆ្ពោះទៅកាន់ថវិកាមួយដែលៈ

- មានលក្ខណៈប្រាកដនិយម ដែលមានន័យថាត្រូវបានរៀបចំ និងអនុវត្តតាមផែនការដោយអាចព្យាករណ៍បាន ។ ចំណាយរដ្ឋាភិបាលគោរពយ៉ាងហ្មឹងម៉ាត់តាមការវិភាជន៍នៅក្នុងថវិកាដែលអនុម័តដោយរដ្ឋសភា ។

- ឆ្លុះបញ្ចាំងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ។

- ដាក់បញ្ចូលប្រតិបត្តិការសារពើពន្ធទាំងអស់ដែលរាជរដ្ឋាភិបាលកម្ពុជា មានសិទ្ធិស្របច្បាប់លើ និង

- ដំណើរការនៅក្នុងប្រព័ន្ធមួយ ដែលនៅក្នុងនោះ ចំណាត់ការគណនេយ្យភាព និងតម្លាភាពហិរញ្ញវត្ថុ ខាងក្រៅកំពុងដំណើរការប្រកបដោយប្រសិទ្ធភាព (ឧទាហរណ៍ សហគមន៍ទទួលព័ត៌មានទៀងទាត់ អំពីថវិកាដែលវិភាជន៍ទៅឱ្យអង្គភាពផ្តល់សេវាកម្ម និងមូលនិធិដែលបានទទួលដោយអង្គភាពទាំងនេះ ។ សវនកម្មពីក្រៅគ្របដណ្តប់លើគ្រប់អង្គភាពវិស័យសាធារណៈសំខាន់ៗ និងអនុវត្តសវនកម្មហិរញ្ញវត្ថុពេញលេញមួយ) ។

# ៣ ថវិកា

ដំណើរការថវិកាមិនមែនគ្រាន់តែគឺជាព្រឹត្តិការណ៍មួយឬឯកសារមួយប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាដំណើរការជាបន្តមួយចាប់តាំងពីការធ្វើផែនការ ការវិភាជន៍ធនធាន ការអនុម័ត ការអនុវត្ត រហូតដល់ការតាមដានលើការអនុវត្ត និងការធ្វើសវនកម្មឯករាជ្យ ។ យោងតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ ១៩៩៣ និងវិធានជាធរមានផ្សេងទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបំពេញតួនាទីនាំមុខគេនៅក្នុងការរៀបចំថវិកា។ ប៉ុន្តែក្រសួង មន្ទីរខេត្ត-ក្រុង និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតក៏ចូលរួមផងដែរនៅក្នុងដំណាក់កាលផ្សេងៗ ផ្អែកលើតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នទាំងនេះ ។

យោងតាមច្បាប់ថវិកាឆ្នាំ ២០០៧ ប្រតិទិនសម្រាប់ការរៀបចំថវិកា រួមមានបីជំហានគឺៈ រៀបចំផែនការយុទ្ធសាស្ត្រ រៀបចំថវិកា និងការអនុម័តថវិកា ។ ប៉ុន្តែវដ្តថវិកាពេញលេញក៏រាប់បញ្ចូលផងដែរនូវការអនុវត្តការតាមដាន និងការគ្រប់គ្រង ក៏ដូចជាដំណាក់កាលចុងក្រោយផងដែរ ដែលគឺជាសវនកម្ម ។ ផ្នែកខាងក្រោមនេះ អធិប្បាយអំពីតួអង្គពាក់ព័ន្ធ សកម្មភាពរបស់តួអង្គទាំងនេះ និងការកំណត់ពេលវេលាសម្រាប់ដំណាក់កាល នីមួយៗៈ ១) រៀបចំផែនការយុទ្ធសាស្ត្រនានា ២) រៀបចំថវិកា ៣) អនុម័តថវិកា ៤) ការអនុវត្តការតាមដាន និងការគ្រប់គ្រងថវិកា និង ៥) ការធ្វើសវនកម្ម។

## ៣.១ រៀបចំផែនការយុទ្ធសាស្ត្រ (ពីខែមីនា ដល់ខែឧសភា)

ដំណាក់កាលនេះគឺជាចំណុចចាប់ផ្តើមនៃដំណើរការថវិកាប្រចាំឆ្នាំ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដោយអនុលោមតាមក្របខ័ណ្ឌគោលនយោបាយជាតិ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការវិភាគលើស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន និងលទ្ធភាពរបស់វានាអនាគតសម្រាប់រយៈពេលខ្លី និងមធ្យម ក៏ដូចជាឧបសគ្គម៉ាក្រូសេដ្ឋកិច្ច ។ ក្របខ័ណ្ឌនេះត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីសុំការឯកភាព ។

ក្រោយពេលគណៈរដ្ឋមន្ត្រីឯកភាពលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យមដែលបានលើកឡើងខាងលើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរមួយជាការណែនាំសម្រាប់ឱ្យក្រសួងនិងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ រៀបចំផែនការថវិកាជាយុទ្ធសាស្ត្ររបស់ខ្លួន។

ក្រសួង ស្ថាប័នរដ្ឋាភិបាល និងមន្ទីរខេត្ត-ក្រុងទាំងអស់ រៀបចំផែនការថវិកាជាយុទ្ធសាស្ត្រមួយ ដោយផ្អែកលើការណែនាំដែលផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកែតម្រូវផែនការនេះស្របតាមចក្ខុវិស័យ គោលបំណង គោលដៅ និងអាទិភាពរបស់ខ្លួនផ្ទាល់ ដែលគប្បីសម្របតាមអាទិភាពតាមវិស័យនានា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

## ៣.២ រៀបចំថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)

នៅដើមខែមិថុនា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំសេចក្តីណែនាំមួយទៀត អំពីនីតិវិធីបច្ចេកទេសសម្រាប់រៀបចំថវិកាតាមវិស័យ ។ សេចក្តីណែនាំនេះត្រូវតែទទួលការអនុម័តដោយគណៈរដ្ឋមន្ត្រីឱ្យបានក្នុងសប្តាហ៍ទីមួយនៃខែមិថុនា ។ បន្ទាប់មកសេចក្តីណែនាំត្រូវផ្ញើជូនស្ថាប័នពាក់ព័ន្ធនានា ដើម្បីឱ្យស្ថាប័នទាំងនោះអាចរៀបចំថវិកាលម្អិតមួយបាន ។ ជាមួយសេចក្តីណែនាំនេះ រដ្ឋមន្ត្រី ប្រធាននៃស្ថាប័នរដ្ឋឯករាជ្យ និងអភិបាលខេត្ត-ក្រុងទាំងអស់ រៀបចំថវិកាលម្អិតរបស់ខ្លួនសម្រាប់ទាំងចំណូល

**រូបភាព ៣.១: ដំណើរការនៃការអនុម័តច្បាប់ថវិកានៅក្នុងរដ្ឋសភា**



និងចំណាយ និងដាក់ថវិកាទាំងនេះជូនក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូល និងបូកសរុបចំណូល និងចំណាយទាំងអស់ ដែលបានស្នើឡើងនៅក្នុងថវិកាលម្អិតទាំងនេះ ។

ខែសីហា ត្រូវបានទុកសម្រាប់ការចរចាថវិកា ។ រដ្ឋមន្ត្រីពីគ្រប់ក្រសួង ប្រធាននៃស្ថាប័នរដ្ឋាភិបាលឯករាជ្យ និងអភិបាលខេត្ត-ក្រុងទាំងអស់ ត្រូវបានអញ្ជើញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យចូលរួមពិភាក្សា និងជជែកគ្នាអំពីសំណើថវិការបស់ខ្លួន ។

នៅក្នុងខែកញ្ញា ក្រោយពេលពិភាក្សា និងជជែកគ្នារួចហើយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំបញ្ចប់តុល្យភាពនៃចំណូលនិងចំណាយក្នុងកម្រិតសមស្រប ។ បន្ទាប់មកសេចក្តីព្រាងច្បាប់ថវិកាជាតិត្រូវបានរៀបចំរួមជាមួយនឹងសេចក្តីពន្យល់ផងដែរ ។

## ៣.៣ អនុម័តថវិកា (ពីខែតុលា ដល់ខែធ្នូ)

យោងតាមច្បាប់ថវិកាឆ្នាំ ២០០៧ នៅក្នុងសប្តាហ៍ទីមួយនៃខែតុលា សេចក្តីព្រាងថវិកាត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីសុំការឯកភាព ។ ក្រោយពេលបានពិនិត្យមើល និងឯកភាពលើសេចក្តីព្រាងថវិកានេះ គណៈរដ្ឋមន្ត្រីបញ្ជូនសេចក្តីព្រាងថវិកានេះជូនរដ្ឋសភា ។ ការដាក់ជូនរដ្ឋសភាត្រូវតែធ្វើនៅក្នុងសប្តាហ៍ទីមួយនៃខែវិច្ឆិកា ។

ក្នុងខែវិច្ឆិកា រដ្ឋសភាពិភាក្សាដេញដោលស្នើឱ្យធ្វើវិសោធនកម្មប្រសិនបើចាំបាច់ និងជាចុងក្រោយអនុម័តថវិកានេះ មុនពេលបញ្ជូនទៅឱ្យព្រឹទ្ធសភា ។ ក្រោយការអនុម័តដោយរដ្ឋសភា សេចក្តីព្រាងច្បាប់ថវិកា ដែលបានអនុម័ត ឬដែលបានធ្វើវិសោធនកម្មនេះ ត្រូវបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យមើល និងផ្តល់អនុសាសន៍ ។ សប្តាហ៍ទីមួយនៃខែធ្នូ ថវិកានេះត្រូវដាក់ជូនព្រឹទ្ធសភា ។ ប្រសិនបើព្រឹទ្ធសភាផ្តល់ការឯកភាព សេចក្តីព្រាងច្បាប់ថវិកាត្រូវធ្វើដោយផ្ទាល់ថ្វាយជូនព្រះមហាក្សត្រ ដើម្បីឡាយព្រះហស្តលេខារួចប្រកាសឱ្យប្រើ ។ ប៉ុន្តែប្រសិនបើ ព្រឹទ្ធសភាសុំឱ្យមានការកែសេចក្តីព្រាងច្បាប់ថវិកានេះត្រូវធ្វើត្រឡប់ទៅរដ្ឋសភាវិញ ។ ពេលនោះរដ្ឋសភាពិនិត្យមើល និងសម្រេចទទួលឬបដិសេធបញ្ញត្តិទាំងអស់ឬមួយចំនួន ឬល័ក្ខខ័ណ្ឌទាំងឡាយដែលព្រឹទ្ធសភាស្នើសុំ ។ ដំណើរការនៃការបញ្ជូនសេចក្តីព្រាងច្បាប់ថវិកាទៅមករវាងរដ្ឋសភានិងព្រឹទ្ធសភា មិនអាចលើសពី ១០ ថ្ងៃ ឡើយ ។ ក្រោយពេលអនុម័តច្បាប់ដោយរដ្ឋសភានិងព្រឹទ្ធសភារួចមក ព្រះមហាក្សត្រឡាយព្រះហស្តលេខា និងប្រកាសឱ្យប្រើច្បាប់ថវិកាដែលបានអនុម័តនោះ ។

ប្រតិទិនសម្រាប់ការរៀបចំថវិកាគឺច្បាស់លាស់ណាស់ ។ ជាគោលការណ៍ប្រសិនបើច្បាប់មិនអាចអនុម័តបាន ច្បាប់សម្រាប់ការគ្រប់គ្រងនៃឆ្នាំមុនអាចអនុវត្តបាន ។ ប្រការនេះមានន័យថាប្រតិទិនថ្មីនេះមិនស្នើឡើងនូវក្របខ័ណ្ឌពេលវេលា សម្រាប់ឱ្យរដ្ឋមន្ត្រីទាំងឡាយកែសេចក្តីព្រាងច្បាប់នេះ ក្នុងករណីដែលមានការបោះឆ្នោតអវិជ្ជមានដោយរដ្ឋសភាឡើយ ។

## ៣.៤ ការអនុវត្តការតាមដាន និងការគ្រប់គ្រង (ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ)

| តារាង ៣.១: ប្រតិទិនថ្មីសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំថវិកាជាតិ | |
|---|---|
| ខែមីនា_ខែឧសភា | • រៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចថ្មី និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យមដែលមានវិចារណកម្មជាមួយនឹងគោលនយោបាយជាតិស្តីពីកិច្ចអភិវឌ្ឍន៍ ដើម្បីសុំការឯកភាពពីគណៈរដ្ឋមន្ត្រី (សប្តាហ៍ទីមួយនៃខែមីនា) ។<br>• ចេញសារាចរស្តីពីរបៀបរៀបចំផែនការថវិកា ជាយុទ្ធសាស្ត្រ អនុលោមតាមគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈ ពេលមធ្យមដែលបានលើកឡើងខាងលើ (សប្តាហ៍ទីមួយខែ មេសា) ។<br>• រដ្ឋមន្ត្រី ប្រធាននៃស្ថាប័នរដ្ឋឯករាជ្យ និងអភិបាលខេត្ត-ក្រុង ត្រូវរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ថវិការបស់ខ្លួន ។ |
| ខែមិថុនា_ខែកញ្ញា | • សេចក្តីព្រាងការណែនាំអំពីរបៀបរៀបចំថវិកា ដែលត្រូវអនុម័តដោយ គណៈរដ្ឋមន្ត្រី (សប្តាហ៍ទីមួយ ខែមិថុនា) ។<br>• រដ្ឋមន្ត្រី ប្រធាននៃស្ថាប័នរដ្ឋាភិបាលឯករាជ្យ និងអភិបាលខេត្ត-ក្រុង ផ្តល់ព័ត៌មានពិស្តារអំពីចំណូលនិងចំណាយរបស់ខ្លួន និងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។<br>• ពិភាក្សាជាមួយរដ្ឋមន្ត្រី ប្រធាននៃស្ថាប័នរដ្ឋាភិបាលឯករាជ្យ និងអភិបាល ខេត្ត-ក្រុងអំពីសំណើរបស់ពួកគេ (ខែសីហា) ។<br>• បញ្ចប់បង្កើយតុល្យភាពនៃចំណូលនិងចំណាយ (ខែកញ្ញា) ។ |
| ខែតុលា_ខែធ្នូ | • សេចក្តីព្រាងច្បាប់សម្រាប់ការគ្រប់គ្រងឆ្នាំនេះត្រូវដាក់ជូនគណៈរដ្ឋមន្ត្រី (សប្តាហ៍ទីមួយនៃខែតុលា) ។<br>• ដាក់សេចក្តីព្រាងច្បាប់នេះជូនរដ្ឋសភា (សប្តាហ៍ទីមួយនៃខែវិច្ឆិកា) ។<br>• ដាក់សេចក្តីព្រាងច្បាប់នេះជូនព្រឹទ្ធសភា (សប្តាហ៍ទីមួយនៃខែធ្នូ) ។ |

ប្រភព: *ច្បាប់ថវិកាជាតិ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧)* ។

ក្រោយពេលដែលថវិកាជាតិត្រូវបានអនុម័តជាច្បាប់រួចហើយរាជរដ្ឋាភិបាលចាប់ផ្ដើមការអនុវត្ត ។ តាមធម្មតាក្រសួង និងស្ថាប័នរដ្ឋាភិបាលឯករាជ្យទាំងអស់ អាចចាប់ផ្ដើមចាយប្រាក់ពីខែមករា ទៅជារៀងរាល់ឆ្នាំ ។ គេឃើញមានវិធីច្រើនដើម្បីទទួលប្រាក់ដែលបានបញ្ចេញសម្រាប់ចំណាយ អាស្រ័យលើប្រភេទ ។ ជាទូទៅ ចំណាយនៅតាមក្រសួងត្រូវបានចែកចេញជាបីប្រភេទៈ

- ប្រាក់សម្រាប់បើកប្រាក់ខែ (បៀវត្សបុគ្គលិក មូលនិធិសោធននិវត្តន៍ និងចំណាយផ្សេងៗទៀតទាក់ទិននឹងបុគ្គលិក) ។ សម្រាប់ចំណាយប្រភេទនេះ ក្រសួងដាក់សំណើជូនរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីសុំការពិនិត្យមើលឡើងវិញ មុនពេលបញ្ជូនសំណើនេះទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីសុំការអនុម័ត ។ ក្រោយពេលដែលសំណើនេះត្រូវបានអនុម័តឯកសារនេះត្រូវផ្ញើទៅកាន់ធនាគារជាតិនៃកម្ពុជាដើម្បីចេញមូលប្បទានប័ត្រ ។

- ចំណាយប្រតិបត្តិការៈ សំណើថវិកាត្រូវបានដាក់ដោយក្រសួងពាក់ព័ន្ធ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយផ្ទាល់ដើម្បីពិនិត្យមើលនិងសម្រេច ។ បន្ទាប់មកធនាគារជាតិនៃកម្ពុជាចេញមូលប្បទានប័ត្រមួយដើម្បីបញ្ចេញប្រាក់ ។

- ចំណាយផ្ទាល់ៈ សម្រាប់ចំណាយប្រភេទនេះ ប្រាក់ត្រូវបានទូទាត់ដោយផ្ទាល់ទៅឱ្យអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ។ ជាធម្មតាចំណាយបែបនេះកើតឡើងតាមរយៈការដេញថ្លៃ ដែលធ្វើដោយក្រសួងពាក់ព័ន្ធផ្អែកលើការណែនាំ និងនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ លទ្ធផលនៃការដេញថ្លៃ ត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីសុំការអនុម័ត ។ ដូចចំណាយប្រភេទផ្សេងទៀតដែរ ក្រោយពេលអនុម័តរួចហើយ ឯកសារនេះត្រូវបញ្ជូនទៅធនាគារជាតិនៃកម្ពុជាដើម្បីបញ្ចេញប្រាក់ ។

ក្រោយពេលប្រាក់ត្រូវបានបញ្ចេញរួចហើយ ផ្អែកលើនីតិវិធីខាងលើនេះ ក្រសួងពាក់ព័ន្ធ/ស្ថាប័នអនុវត្ត នឹងអនុវត្តសកម្មភាពនោះ ដោយគោរពតាមការណែនាំហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅក្នុងស្ថាប័នសាធារណៈនីមួយៗអនុវត្តការគ្រប់គ្រងផ្ទៃក្នុងលើចំណាយសាធារណៈនៅក្នុងពេលអនុវត្ត ។ ក្រសួងពាក់ព័ន្ធ និងស្ថាប័នរដ្ឋាភិបាលឯករាជ្យផ្សេងទៀត គឺជាអ្នកអនុវត្តថវិកាជាតិជាក់ស្ដែង ។

- នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ចែកចាយថវិកាជូនគ្រប់ក្រសួង និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតទាំងអស់ដើម្បីអនុវត្ត ។ នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុក៏តាមដានផងដែរនូវការអនុវត្តចំណូល និងចំណាយ យោងតាមថវិកាដែលបានវិភាជន៍ឱ្យក្រសួង ស្ថាប័ន និងខេត្ត/ឃុំ ។

- អគ្គាធិការ ធ្វើអធិការកិច្ចទូទៅចំពោះក្រសួង និងស្ថាប័នរដ្ឋាភិបាលលើប្រតិបត្តិការចំណាយ និងគណនេយ្យភាពរបស់អ្នកគ្រប់គ្រងមូលនិធិសាធារណៈ ។ អគ្គាធិការក៏ធ្វើអធិការកិច្ចផងដែរលើ

ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់របស់ស្ថាប័នសាធារណៈ និងសហគ្រាសរដ្ឋ ។ល។ អគ្គាធិការធ្វើការស៊ើបអង្កេតលើការតវ៉ា និងពាក្យបណ្តឹងដែលធ្វើឡើងដោយប្រជាពលរដ្ឋទាក់ទិននឹងការគ្រប់គ្រងសេដ្ឋកិច្ច និងអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ។

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅក្នុងស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈនីមួយៗ ត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យលើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។ នាយកដ្ឋានទាំងនេះធានាឱ្យបានថា ការរាយការណ៍ហិរញ្ញវត្ថុដែលអាចទុកចិត្តបាន ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងធានាឱ្យបានថា ប្រតិបត្តិការនានាគឺគោរពតាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធីជាធរមាននានា ។

## ៣.៥ ការធ្វើសវនកម្មថវិកា

អាជ្ញាធរសវនកម្មជាតិ ដែលគឺជាអង្គភាពសាធារណៈឯករាជ្យមួយ ទទួលបន្ទុកលើមុខងារធ្វើសវនកម្មខាងក្រៅរបស់រាជរដ្ឋាភិបាល ។ អគ្គសវនករមានសមត្ថកិច្ចធ្វើសវនកម្មលើឯកសារគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការគ្រប់គ្រងប្រតិបត្តិការ និងកម្មវិធីនានារបស់ស្ថាប័នរដ្ឋាភិបាល អនុលោមតាមស្តង់ដារសវនកម្មដែល គេទទួលស្គាល់ជាទូទៅ និងស្តង់ដារ[៥] សវនកម្មរបស់រាជរដ្ឋាភិបាល ។ សវនកម្មខាងក្រៅ រួមមានការអនុវត្តប្រភេទសវនកម្មដូចខាងក្រោមនេះ

- សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- សវនកម្មលើការគ្រប់គ្រងគម្រោងគណទានដែលផ្តល់ហិរញ្ញប្បទានដោយប្រភពខាងក្រៅ
- សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការនានារបស់គ្រប់ស្ថាប័នទាំងអស់
- សវនកម្មលើការវាយតម្លៃប្រសិទ្ធផល និងប្រសិទ្ធភាពនៃប្រតិបត្តិការ ។

ដំណើរការសវនកម្មត្រូវបានដឹកនាំដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។ យោងតាមច្បាប់នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំជូនរដ្ឋសភា និងព្រឹទ្ធសភាដើម្បីពិនិត្យ និងឯកភាព ។ របាយការណ៍ទាំងនេះក៏ត្រូវដាក់ជូនអាជ្ញាធរសវនកម្មជាតិផងដែរ ដើម្បីធ្វើសវនកម្ម ក្នុងរយៈពេលប្រាំបួនខែក្រោយពេលបិទឆ្នាំហិរញ្ញវត្ថុ ។ អាជ្ញាធរសវនកម្មជាតិរៀបចំរបាយការណ៍សវនកម្មមួយ និងដាក់ របាយការណ៍នេះជូនរដ្ឋសភា និងព្រឹទ្ធសភា ។ រដ្ឋសភាបញ្ចប់ដំណើរការសវនកម្មដោយមធ្យោបាយអនុម័តច្បាប់ទូទាត់ថវិកា ។ នៅក្នុងវិធីនេះសេចក្តីសន្និដ្ឋានត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការអនុវត្តថវិកាបានល្អ ឬមិនគួរឱ្យពេញចិត្ត ។

---

*[៥] មាត្រា ១ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ។*

# ៤ និន្នាការនៃថវិកាកម្ពុជា

ដើម្បីណែនាំបង្ហាញពីការប្រើប្រាស់ធនធាន រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ដែលមានរយៈពេលប្រាំឆ្នាំ ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្របច្ចុប្បន្ន គឺសម្រាប់រយៈពេលពីឆ្នាំ២០០៦ ដល់២០១០ ។ ផែនការនេះត្រូវអនុវត្តតាមរយៈថវិកាជាតិ និងកម្មវិធីវិនិយោគសាធារណៈដែលត្រូវបានរំពឹងថា នឹងជួយបង្ហាញណែនាំដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិត្រូវបានបញ្ជាក់ដោយនាយករដ្ឋមន្ត្រីថាជា "ប្លង់សម្រាប់ការរីកចម្រើនជាបន្ត" និងជា "ឯកសារគ្របដណ្តប់ទាំងអស់តែមួយគត់សម្រាប់ រយៈពេលប្រាំឆ្នាំក្រោយ" ។ គេបានទទួលស្គាល់ថា វាជាយុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ដែលមានចំណុចអាទិភាពផ្នែកគោលនយោបាយសេដ្ឋកិច្ចសង្គមសំខាន់ៗ គឺត្រូវសម្រេចឱ្យបាននូវ : ការបំបាត់ភាពក្រីក្រខ្លាំង និងភាពអត់ឃ្លាន ការអប់រំមូលដ្ឋានរយៈពេលប្រាំបួនឆ្នាំជាសកល ការបង្កើនសមភាពយេនឌ័រ និងការកាត់បន្ថយមរណភាពកុមារ ។ គោលនយោបាយ និងផែនការថ្មីៗជាច្រើនត្រូវបានបង្កើតឡើង ដើម្បីសម្រេចគោលដៅទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យកាន់តែមានអត្ថន័យជាងនេះ គោលនយោបាយ និងផែនការតាមផ្នែក ត្រូវផ្សារភ្ជាប់ទៅនឹងថវិកា ដែលជាមធ្យោបាយដ៏សំខាន់បំផុតរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយគោលនយោបាយទាំងនេះឱ្យទៅជាសកម្មភាពជាក់ស្តែង ។ ប្រអប់ ៤.១ រៀបរាប់អំពីការលំបាកមួយចំនួនដែលរដ្ឋសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជួបប្រទះនៅពេលធ្វើសេចក្តីសម្រេចចិត្តលើការចំណាយសាធារណៈ ។

**ប្រអប់ ៤.១ : ការលំបាកដែលរាជរដ្ឋាភិបាលជួបប្រទះនៅក្នុងការបែងចែកចំណាយ**

ដំណើរការនៃការរៀបចំថវិកា ដើម្បីប្រែក្លាយគោលនយោបាយឱ្យទៅជាសកម្មភាពជាក់ស្តែង និងដើម្បីសម្រេចបានលទ្ធផលដែលចង់បាន និងគោលដៅ មានលក្ខណៈសាំញ៉ាំ ហើយត្រូវការការវិភាគយ៉ាងល្អិតល្អន់ ។ ជាមួយនឹងធនធានមានកម្រិត រាជរដ្ឋាភិបាលកម្ពុជា ត្រូវការជ្រើសរើសរវាងការវិនិយោគលើរដ្ឋបាលរបស់រដ្ឋាភិបាល ផ្នែកសេដ្ឋកិច្ច (កសិកម្ម ដឹកជញ្ជូន សាធារណការ និងអភិវឌ្ឍន៍ជនបទ) និងផ្នែកសង្គម (អប់រំ សុខាភិបាល ការការពារសង្គម និងសេវាសង្គមផ្សេងៗទៀត) ។

ដូចបានបញ្ជាក់ដោយធនាគារពិភពលោក (2007) ការផ្តល់អនុសាសន៍ទាក់ទងនឹងអ្វីដែលជាការបែងចែកដ៏ល្អបំផុតសម្រាប់ការចំណាយរបស់រដ្ឋាភិបាល គឺជាការលំបាក ។ ហេតុផលមួយសម្រាប់បញ្ហានេះ គឺថាការបង្កើនលើការចំណាយមូលធន (ការកសាងផ្លូវ/សាលារៀន/មន្ទីរពេទ្យ) អាចធ្វើទៅបានសមស្រប ប្រសិនបើរដ្ឋាភិបាលមានបុគ្គលិកគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង ដែលមានន័យថា ការចំណាយចរន្តបន្ថែម (ប្រាក់ឈ្នួល/ចំណាយប្រតិបត្តិការ) អាចជាការចាំបាច់ ។ ដូច្នេះ គេមិនទាន់ដឹងច្បាស់បានភ្លាមៗថា តើការចំណាយមូលធន ត្រូវបាននិយមប្រើប្រាស់ជាងចំណាយចរន្តឬក៏អត់ទេ ។ បញ្ហាមួយទៀតគឺថា ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ គឺជាការបំពេញបន្ថែមចំពោះចំណាយផ្នែកសង្គម ។ ដូច្នេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអត្រាចុះ ឈ្មោះចូលរៀននៅក្នុងស្រុកជាក់លាក់ណាមួយនោះ ការកសាងផ្លូវអាចជួយបានច្រើនជាងការកសាងសាលារៀនមួយទៅទៀត ។ ជាលទ្ធផលគេនៅមិនទាន់ដឹងច្បាស់ភ្លាមៗថា តើផ្នែកអ្វីខ្លះត្រូវទទួលបានអាទិភាពក្នុងការសម្រេចគោលបំណងផ្នែកសង្គមណាមួយនៅឡើយទេ ។

ទោះបីជាមានការលំបាកទាំងនេះក៏ដោយ ក៏រដ្ឋាភិបាល និងរដ្ឋសភា ត្រូវការធ្វើសេចក្តីសម្រេចចិត្តលើការបែងចែកថវិកាជារៀងរាល់ឆ្នាំ ។ ដើម្បីអាចធ្វើសេចក្តីសម្រេចចិត្តបានល្អបំផុត ទាំងរដ្ឋាភិបាល ទាំងរដ្ឋសភា ត្រូវមានព័ត៌មានច្រើនតាមដែលអាចធ្វើបាន ។ អាស្រ័យហេតុនេះ វាមានប្រយោជន៍ផ្នែកសេដ្ឋកិច្ច ក្នុងការស្តាប់ដោយយកចិត្តទុកដាក់នូវតម្រូវការរបស់ប្រជាពលរដ្ឋ តាមរយៈការពិគ្រោះយោបល់ជាមួយពួកគាត់ និងការចូលរួមជាមួយអង្គការសង្គមស៊ីវិល ។

## ៤.១ និន្នាការលើចំណូល

ផ្នែកចំណូលក្នុងស្រុករបស់ថវិកាមានចំណូលចរន្ត និងចំណូលមូលធន (សូមមើលផ្នែក២.៣) ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ចំណូលមូលធនក្នុងស្រុកមានចំនួនតិចតួចបំផុត ។ ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៤ ចំណូលមូលធន បានរួមចំណែកតិចជាង២ភាគរយ នៃចំណូលក្នុងស្រុកសរុប ក្រៅពីនោះត្រូវបានរួមចំណែកដោយ ចំណូលចរន្ត ។ ប្រភពនៃមូលធនក្នុងស្រុក រាប់បញ្ចូលទាំងការធ្វើឯកជនភាវូបនីយកម្ម ការលក់អចលនទ្រព្យ (ឧទាហរណ៍ ឯកជនភាវូបនីយកម្មលើចំការកៅស៊ូ និងការលក់ដីសាធារណៈ ។ នៅក្នុងច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ធនធានទាំងនេះ ត្រូវបានចាត់ចំណាត់ថ្នាក់ជាចំណូលចរន្ត) និងការខ្ចីប្រាក់ក្នុងស្រុក ។ ចំណែកនៃចំណូលមូលធន បានកើនឡើងដល់៥.៨ ភាគរយនៅក្នុងឆ្នាំ២០០៥ ភាគច្រើនដោយសារការកើនឡើងនៃចំណូលពីឯកជនភាវូបនីយកម្ម ពី៩ពាន់លានរៀល (២.២ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៤ ដល់ ១៣៣.៦ ពាន់លានរៀល (៣២.១ លានដុល្លា ស.រ.អ) នៅក្នុងឆ្នាំ២០០៦។ ចំណូលមូលធនបានបន្តកើនឡើងរហូតដល់១១.៦ ភាគរយនៃចំណូលក្នុងស្រុកសរុប ដោយសារការទទួលបានពីគម្រោងបន្ធូរបន្ថយបំណុលពហុភាគី (MDRI)[៦] ដោយឥតបានរំពឹងទុក ។

---

[៦] *នៅក្នុងខែមករា ឆ្នាំ២០០៦ ក្រោមគម្រោងបន្ធូរបន្ថយបំណុលពហុភាគី IMF បានលុបចោលនូវបំណុលដែលកម្ពុជា ជំពាក់មានតម្លៃស្មើ៨២ លានដុល្លារអាមេរិក ។*

**រូបភាព ៤.១ : ចំណែកនៃចំណូលពីពន្ធនៅក្នុងឆ្នាំ២០០៦**




**ប្រភព:** *គណនាផ្អែកទៅតាមការអនុវត្តថវិកាឆ្នាំ២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងទាំងនេះមិនអាចចាត់ទុកថាជាការផ្លាស់ប្តូរធំដុំចំពោះនិន្នាការនៃការប្រមូលចំណូលទេ ។ តាមនិយមន័យ ការកើនឡើងនៃចំណូលមូលធន គ្មានស្ថេរភាព និងខុសគ្នាយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។ លើសពីនេះទៀត ភាគច្រើនចំណូលមូលធន កើតឡើងតែមួយពេលៗប៉ុណ្ណោះ ។

ចំណូលចរន្តសម្រាប់ឆ្នាំ២០០៦ គឺមានចំនួន ២.៨៨១,៧ ពាន់លានរៀល (៧០១,៧ លានដុល្លារ ស.រ.អ) ដោយឡើងដល់៩,៨ភាគរយនៃផលទុនក្នុងស្រុកសរុប (GDP) ។ នេះបានបង្ហាញឱ្យឃើញនូវការកើនឡើងចំនួន ១៦,៥ ភាគរយ បើប្រៀបធៀបជាមួយឆ្នាំ២០០៥ ។ ចំណូលពីពន្ធ គឺជាប្រភពចំបងនៃចំណូលចរន្ត ។ ចំណូលនេះ មានចំនួន៧៨,៨ ភាគរយនៃចំណូលចរន្តសរុបនៅក្នុងឆ្នាំ២០០៦ ស្មើនឹង៧,៧ភាគរយ នៃផលទុនក្នុងស្រុកសរុប ។

រដ្ឋាភិបាល ប្រមូលពន្ធបីប្រភេទផ្សេងៗគ្នា :

១. ពន្ធដោយផ្ទាល់ ដែលត្រូវបានបង់ដោយផ្ទាល់ទៅឱ្យរដ្ឋាភិបាលរាប់បញ្ចូលទាំងពន្ធលើបៀវត្សពន្ធលើប្រាក់ចំណេញ និងពន្ធដី ព្រមទាំងពន្ធលើអចលនទ្រព្យ ។ ពន្ធដោយផ្ទាល់ដែលត្រូវបានប្រមូលនៅក្នុងឆ្នាំ២០០៦ មានចំនួន៣៣១ ពាន់លានរៀល (៨០,៥ លានដុល្លារ ស.រ.អ) ដែលស្មើនឹង ១៦២ ភាគរយនៃផែនការថវិកា ។ ចំនួននេះ បានកើនឡើងក្នុងកម្រិតមួយដែលគួរឱ្យចាប់អារម្មណ៍ គឺ៤៩ ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំមុន ។

២. ពន្ធប្រយោល គឺជាប្រភពដ៏ចំបងនៃចំណូលពីពន្ធសម្រាប់រយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ។ ចំណូលទាំងនេះ ស្មើនឹង៥៧ភាគរយនៃចំណូលពីពន្ធនៅក្នុងឆ្នាំ២០០៦ លើសឆ្នាំ២០០៥ ចំនួន ១៦ ភាគរយ និង៤,៤ ភាគរយនៃផលទុនក្នុងស្រុកសរុប ។ពន្ធប្រយោល ត្រូវបានបង់ទៅឱ្យភាគីទីពីរ

ដែលបន្ទាប់មក បន្តបង់ពន្ធទាំងនេះទៅឱ្យរដ្ឋាភិបាល ។ ពន្ធទាំងនេះ រួមមានពន្ធលើផលរបរ ពន្ធលើអាករបន្ថែម និងពន្ធគយលើទំនិញ និងសេវាកម្ម ដូចជាពន្ធលើការនាំចូលសាំង អាករលើគ្រឿងស្រវឹង និងបារី ។ល។ ពន្ធលើអាករបន្ថែមតែមួយមុខ ស្មើនឹង៦៦,១ ភាគរយនៃពន្ធប្រយោលសរុបនៅក្នុងឆ្នាំ ២០០៦ ។

៣. ពន្ធពាណិជ្ជកម្មអន្តរជាតិ មានពន្ធគយ និងពន្ធលើទំនិញនាំចូល និងនាំចេញ ។ នៅក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលបានប្រមូលទឹកប្រាក់ចំនួន ៦៤៤,៤ ពាន់លានរៀល (៨០,៥ លានដុល្លារ ស.រ.អ) ជាពន្ធលើពាណិជ្ជកម្មអន្តរជាតិច្រើនជាងឆ្នាំ២០០៥ ចំនួន១២,៥ ភាគរយ ។ ប៉ុន្តែ ចំណែកនៃពន្ធនេះលើផលទុនក្នុងស្រុកសរុប បានថយចុះបន្តិចបន្តួច ពី២,២ភាគរយ ដល់២,១ ភាគរយ ដោយសារកំណើនផលទុនក្នុងស្រុកសរុបឆាប់រហ័ស (១០,៨ ភាគរយនៅក្នុងតម្លៃថេរនៃឆ្នាំ២០០០) ។

ចំណូលមិនមែនពន្ធ មានចំណូលពីផលផលព្រៃឈើ ថ្លៃក្រុមហ៊ុន (ឧទាហរណ៍ ក្រុមហ៊ុនប្រេង) បង់ជូនរដ្ឋ ប្រៃសណីយ៍ និងទូរគមនាគមន៍ ថ្លៃទិដ្ឋាការ ប្រាក់ចំណេញពីធនាគារកិច្ច ។ល។ នៅក្នុងឆ្នាំ២០០៦ ចំណូលមិនមែនពន្ធ បានកើនឡើងដល់៦១០,៩ ពាន់លានរៀល (១៤៨,៧ លានដុល្លារ ស.រ.អ) ស្មើនឹង ៨,៦ ភាគរយច្រើនជាងឆ្នាំ២០០៥ និងស្មើនឹង២,១ភាគរយនៃ GDP ។ ប្រភពសំខាន់ៗចំនួនប្រាំនៃចំណូលមិនមែនពន្ធនៅក្នុងឆ្នាំ២០០៦ គឺថ្លៃទិដ្ឋាការ (៩៥,៣ ពាន់លានរៀល/២៣,២ លានដុល្លារ ស.រ.អ) ការលក់ឡាយឡុងកូតា និងអាជ្ញាប័ណ្ណនាំចេញ (៨៨,៤ ពាន់លានរៀល/២១,៥ លានដុល្លារ ស.រ.អ) ប្រៃសណីយ៍ និងទូរគមនាគមន៍ ៨៣ ពាន់លានរៀល/២០,២ លានដុល្លារ ស.រ.អ) កាស៊ីណូ (៧៧ ពាន់លានរៀល/១៨,៧ លានដុល្លារ ស.រ.អ) និងទេសចរណ៍ (៥៩,២ ពាន់លានរៀល/១៤,៤ លានដុល្លារ ស.រ.អ) ។

ដូចគ្នានឹងចំណូលពីពន្ធដែរចំណូលមិនមែនពន្ធ បានកើនឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០០០ មក ។ នៅក្នុងឆ្នាំ២០០០ ចំណូលមិនមែនពន្ធស្មើនឹង២៥,២ ភាគរយនៃចំណូលក្នុងស្រុកសរុប ។ ចំណូលនេះបានកើនឡើងដល់២៩,៦ ភាគរយនៅក្នុងឆ្នាំ២០០៣ ប៉ុន្តែ បានធ្លាក់ចុះមកនៅត្រឹម២១,២ ភាគរយនៅក្នុងឆ្នាំ២០០៦ ។

ជាទូទៅប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្ហាញនូវការរីកចម្រើនយ៉ាងច្រើន នៅក្នុងការប្រមូលចំណូលចរន្តក្នុងស្រុក ។ ចំនួននៃចំណូលបានកើនឡើងយ៉ាងគួរឱ្យកត់សំគាល់ ។ បើគិតជាតួលេខពិត ចំណូលដែលប្រមូលបាននៅក្នុងឆ្នាំ២០០៤ បានបង្ហាញពីការកើនឡើងចំនួន២២ ភាគរយ បើប្រៀបធៀបជាមួយឆ្នាំ២០០៣ ។ ការកើនឡើងនេះបានបន្តនៅត្រឹម១៧ ភាគរយ និង១៤ភាគរយ នៅក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៦ ដោយឡែកៗពីគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលប្រៀបធៀបជាមួយផលទុនក្នុងស្រុកសរុប និន្នាការនេះមិនបង្ហាញនូវការរីកចម្រើនធំដុំទេ ។ផលធៀបចំណូលចរន្ត/ផលទុនក្នុងស្រុកសរុបស្ទើរតែនៅដដែល ដោយមានការប្រែប្រួលប្រមាណ ៩,៥ និង១០ភាគរយ ចាប់តាំងពីឆ្នាំ២០០០ មក ។ ក្រៅពីបណ្តាលមកពីបញ្ហាអភិបាលកិច្ច ការកើនឡើងនេះកើតឡើងភាគច្រើនដោយសារកំណើនសកម្មភាពសេដ្ឋកិច្ចឆាប់រហ័ស រាប់បញ្ចូលទាំងកសិកម្ម និងឧស្សាហកម្មកាត់ដេរ ដែលរួចពន្ធយ៉ាងច្រើនផង ។

វាជាការសំខាន់ដែលត្រូវកត់សំគាល់ថា ចំណូលក្រៅថវិកា គឺជាការសំខាន់ (World Bank and IMF, 2005) ។ ចំណូលទាំងនេះភាគច្រើន គឺជាចំណូលមិនមែនពន្ធដារដែលត្រូវបានប្រមូលដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងត្រូវបានប្រើដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ស្ថាប័នរបស់គេផ្ទាល់ ។ ការចាប់យកចំណូលក្រៅថវិកាទាំងនេះ ពិតជាអាចជួយបង្កើនផលធៀបចំណូលចរន្ត/ផលទុនក្នុងស្រុកសរុប ព្រមទាំងបង្កើនតម្លាភាពទៀតផង ។ ការបញ្ចូលចំណូលក្រៅថវិកាទៅក្នុងថវិកា ត្រូវបានមើលឃើញមាននៅក្នុងផែនការសកម្មភាពមួយរបស់កម្មវិធី កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ប៉ុន្តែ រហូតមកដល់ពេលនេះ ការរីកចម្រើននៅមានភាព យឺតយ៉ាវនៅឡើយ ដោយសារកង្វះខាតកិច្ចសហប្រតិបត្តិការពីក្រសួងពាក់ព័ន្ធ ។

នៅត្រឹមឆ្នាំ២០០៩ រដ្ឋាភិបាលមានបំណងធ្វើឱ្យប្រសើរឡើងនូវការប្រមូលចំណូល ដើម្បីឈានទៅដល់ កំណើនផលទុនក្នុងស្រុកសរុប១២,៥ ភាគរយ ។

**រូបភាព ៤.២ : ចំណូលក្នុងស្រុក : ពន្ធ មិនមែនពន្ធ និងមូលធន ២០០០-២០០៦ ជាដុល្លារ ស.រ.អ (លាន)**




ប្រភព: *គណនាផ្អែកទៅលើទិន្នន័យដែលទទួលបានពីការអនុវត្តថវិកាឆ្នាំ២០០០-២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអត្រាប្តូរប្រាក់ជាផ្លូវការ ដែលទទួលបានពីព្រឹត្តិប័ត្រស្ថិតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ១៣៩ ខែកក្កដា ឆ្នាំ២០០៧ ។*

## ៤.២ និន្នាការលើការចំណាយ

ដូចបានពោលពីខាងដើម ការធ្វើវិភាជន៍ គួរតែត្រូវបានណែនាំបង្ហាញដោយផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដែលមានគោលបំណង "កាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស និងសម្រេចគោលដៅ

អភិវឌ្ឍន៍សហសវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមផ្សេងទៀត ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប" ។ ដើម្បីសម្រេចគោលបំណងដែលបានគ្រោងទុក ការចំណាយរបស់រដ្ឋាភិបាលត្រូវតែគាំទ្រជនក្រីក្រ ដែលមានន័យថា ការចំណាយនេះគួរតែសំដៅកាត់បន្ថយភាពក្រីក្រ ។ ទោះបីជានិយមន័យពិតប្រាកដទាក់ទងនឹងថា តើចំណាយដូចម្តេចនៅក្នុងថវិកាដែលគាំទ្រជនក្រីក្រ មិនអាចរកបានក៏ដោយ មានការព្រមព្រៀងជាទូទៅថា ការចំណាយដែលមានគោលបំណងជំរុញកសិកម្មខ្នាតតូច លើកកំពស់ការថែទាំសុខភាពមូលដ្ឋាន គាំទ្រចំពោះការអប់រំបឋម និងមធ្យមសិក្សា កែលំអលទ្ធភាពទទួលបានទឹកស្អាត និងធ្វើឱ្យអនាម័យបានល្អប្រសើរឡើងចាត់ចូលក្នុងប្រភេទនេះ ។

ដើម្បីប្រែក្លាយទស្សនាទានគាំទ្រជនក្រីក្រឱ្យទៅជាការពិត រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ក្រសួងចំនួន ប្រាំពីរជាអាទិភាពi) ក្រសួងអប់រំ យុវជន និងកីឡាii) ក្រសួងសុខាភិបាលiii) ក្រសួងកិច្ចការនារី iv) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ v) ក្រសួងអភិវឌ្ឍន៍ជនបទ vi) ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម និងសំណង់ និងvii) ក្រសួងយុត្តិធម៌ ។ ការផ្តល់ស្លាកសញ្ញា "អាទិភាព" ដល់ក្រសួងទាំងនេះ លើកឡើងនូវការរំពឹងទុកថា ថវិការបស់ក្រសួងទាំងនេះ នឹងត្រូវទទួលបានអាទិភាពជាងវិស័យដែល "មិនមែនអាទិភាព" ។ ឧទាហរណ៍ វាជាការសមហេតុផលដែលត្រូវរំពឹងទុកថា ថវិការបស់ក្រសួងអាទិភាពនឹងទទួលបានអាទិភាពទី១ ក្នុងករណីដែល មានលុយបន្ថែមនៅក្នុងថវិកាជាតិ ។

ការវិភាគដែលបានបង្ហាញខាងក្រោម ផ្តល់នូវទិដ្ឋភាពទូទៅនៃនិន្នាការ នៅក្នុងថវិការបស់រដ្ឋាភិបាល និងប្រៀបធៀបការធ្វើវិភាជន៍ទៅឱ្យវិស័យអាទិភាពជាមួយនឹងផ្នែកដែលមិនមែនអាទិភាព និងរៀបរាប់ អំពីនិន្នាការនៅក្នុងការធ្វើវិភាជន៍ទៅឱ្យវិស័យអាទិភាពនីមួយៗ ។ ទោះបីជាយ៉ាងណាក៏ដោយ គេត្រូវការកត់សំគាល់ត្រង់នេះថា ការប៉ុនប៉ងដើម្បីវិភាគលើនិន្នាការទូទៅនៃការចំណាយរបស់រដ្ឋាភិបាល ( ទាំងចំណាយចរន្ត ទាំងចំណាយមូលធន) នៅក្នុងវិស័យផ្សេងៗ គឺជាការលំបាកដោយសារកង្វះខាតទិន្នន័យស្តីពីការអនុវត្តថវិកានៅ ក្នុងការចំណាយមូលធន ។ ហេតុផលសម្រាប់បញ្ហានេះ គឺថាមានប្រភពនៃការផ្តល់មូលនិធិពីរសម្រាប់ការចំណាយមូលធនៈ ការវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញវត្ថុក្នុងប្រទេស ( ត្រូវបានអនុវត្តនៅក្នុងថវិកា) និងការវិនិយោគដែលផ្តល់ ហិរញ្ញវត្ថុពីខាងក្រៅដោយផ្ទាល់ ( ត្រូវបានអនុវត្តដោយផ្ទាល់ដោយម្ចាស់ជំនួយ ដូច្នេះហើយស្ថិតនៅក្រៅថវិកា) ។ សមាមាត្រនៃការផ្តល់ហិរញ្ញវត្ថុពីខាងក្រៅដោយផ្ទាល់នៅក្នុងថវិកាមូលធនសរុបមានកម្រិតខ្ពស់ណាស់ ។ នៅក្នុងច្បាប់ថវិកា ចំនួននេះស្មើនឹង៧៥.២ភាគរយ នៃការចំណាយមូលធនសរុបនៅក្នុងឆ្នាំ ២០០៤ និង ៧២.៩ ភាគរយ នៅក្នុង ឆ្នាំ២០០៦ ។ ចំណែកដ៏ធំនៃការចំណាយមូលធនទាំងនេះ ត្រូវបានប្រតិបត្តិការនៅក្រៅរតនាគារជាតិ ។ បច្ចុប្បន្ន ដោយពិចារណាលើលក្ខណៈនៃការអនុវត្តនេះ សូម្បីតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានទិន្នន័យតិចតួចបំផុតអំពីការចំណាយប្រភេទនេះដែរ ។ បញ្ហាដែលទាក់ទិនជាមួយចំនួនដ៏ច្រើន នៃការចំណាយក្រៅថវិកានេះ នឹងក្លាយជាប្រធានបទនៃការងារនាពេលអនាគតនៅក្នុងគម្រោងថវិការបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum on Cambodia) ។

## ៤.២.១ ចំណាយចរន្ត ( ថវិកាដែលត្រូវបានអនុវត្ត)

រូបភាពទី៤.៣ ខាងក្រោម បង្ហាញពីទិដ្ឋភាពទូទៅនៃការចំណាយចរន្តជាក់ស្តែងពីឆ្នាំ២០០០ ដល់

ឆ្នាំ២០០៦ ជាបួនប្រភេទដ៏ទូលំទូលាយ : រដ្ឋបាលទូទៅ ការពារជាតិ និងសន្តិសុខ វិស័យអាទិភាព វិស័យផ្សេងៗ[៧] (មិនមែនអាទិភាព) ។ តួលេខនេះបង្ហាញថា ចំណាយចរន្តលើការការពារជាតិ និងសន្តិសុខ បើគិតជាចំណែកនៃចំណាយចរន្តសរុប បានធ្លាក់ចុះដ៏គួរឱ្យកត់សំគាល់ពី៣៧,២ ភាគរយ ដល់ ២១,៩ ភាគរយ ។ ការចំណាយចរន្ត ទៅលើរដ្ឋបាលទូទៅ (មិនរាប់បញ្ចូលវិស័យយុត្តិធម៌) បានធ្លាក់ចុះពី២២,៣ ភាគរយ ដល់១៧,៤ ភាគរយ ដែលជាចំណែកនៃការចំណាយចរន្តសរុប ។ ចំណែកនៃវិស័យអាទិភាពទាំងប្រាំពីរបានកើនឡើងពី៣០.៦ ភាគរយដល់ ៣៥,៣ ភាគរយក្នុងរយៈពេលដូចគ្នា ។ ប៉ុន្តែស្របពេលជាមួយគ្នានេះការចំណាយចរន្តលើវិស័យ ផ្សេងៗទាំងអស់(មិនមែនអាទិភាព) បានកើនឡើងក្នុងកម្រិតដ៏ឆាប់រហ័សពី៩,៩ភាគរយដល់២៥,៤ ភាគរយនៅក្នុងឆ្នាំ២០០៦ ។

ដូចបានបង្ហាញនៅក្នុងតារាងនៅក្នុងឧបសម្ព័ន្ធ៤ ចំណាយចរន្តរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំ២០០៦ បានកើនឡើងដល់ ១.៩៣៧.៥៨៣,៧ លានរៀល (៤៧១,៧ លានដុល្លារ ស.រ.អ) ដែលជាការកើនឡើង៦៥ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០០០ ។ ដូចបង្ហាញនៅក្នុងតារាងដដែល ការចំណាយលើ

**រូបភាព ៤.៣ : ចំណាយចរន្ត ចំណែកនៅតាមវិស័យ ២០០០-២០០៦ (%)**




**ប្រភព:** *គណនាផ្អែកទៅលើការអនុវត្តថវិកាឆ្នាំ២០០០-២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

[៧] *ជំពូកនៃវិស័យផ្សេងៗ (មិនមែនអាទិភាព) មានដូចតទៅនេះ : វប្បធម៌ និងវិចិត្រសិល្បៈ បរិស្ថាន ព័ត៌មាន ។ ជំពូកនៃវិស័យ ផ្សេងទៀត (មិនមែនអាទិភាព) មាន : ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធម្មការ និងសាសនា សង្គមកិច្ច ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ពាណិជ្ជកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល ប្រៃសណីយ៍ និងទូរគមនាគមន៍ សាធារណការ និងដឹកជញ្ជូន ទេសចរណ៍ ធនធានទឹក និងឧតុនិយម និងមុខចំណាយទាំងអស់ដែលស្ថិតក្នុងក្រុមដែលមានចំណងជើងថា ផ្សេងៗ ។*

វិស័យសង្គមសំខាន់ៗ បានពង្រីកត្រឹម៩០ភាគរយ ក្នុងអំឡុងពេលដូចគ្នា ប៉ុន្តែក្រសួងអាទិភាពជាច្រើន មិនបានទទួលអត្ថប្រយោជន៍ពីការចំណាយនេះដោយស្មើគ្នាទេ ដូចដែលមានបង្ហាញក្នុងតារាង ៤.១ ខាងក្រោម ។

ចំណាយចរន្តជាក់ស្តែងលើការអប់រំបានកើនឡើងត្រឹម៩០ ភាគរយរវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ ។ ដោយវាជាចំណែកនៃចំណាយចរន្តសរុប ចំណាយនេះបានកើនឡើងត្រឹម៤ភាគរយ ពី១៤,៨ ភាគរយ ដល់ ១៨,៨ភាគរយក្នុងរយៈពេលនេះ ។

ចំណាយចរន្តនៅក្នុងវិស័យសុខាភិបាល បានបង្កើនត្រឹម១០៩ភាគរយ រវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ រីឯចំណែកនៃវិស័យនេះនៅក្នុងចំណាយចរន្តសរុបបានកើនឡើងពី៧,៩ភាគរយ នៅក្នុងឆ្នាំ២០០០ ដល់ ១១,៣ភាគរយ នៅក្នុងឆ្នាំ២០០៦ ។ ដោយគិតវាជាចំនួនចំណាយនេះបានកើនឡើងលើសពីពីរដង ពី៩២.៨២៨ លានរៀល (២៣,៨ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០០ ដល់២១៩.១២៣,៣ លានរៀល (៥៣,៣ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៦ ។ លើសពីនេះទៀតគួរកត់សំគាល់ថា នៅក្នុងឆ្នាំ២០០៦ វិស័យសុខាភិបាល និងអប់រំ បញ្ចូលគ្នាស្មើនឹង៤៥ភាគរយ នៃចំណាយចរន្តទាំងអស់ នៅក្នុងវិស័យអាទិភាពទាំងប្រាំពីរ ។

ការចំណាយចរន្តលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកើនឡើងទ្វេដងរវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ ហើយបានកើនឡើងដល់ ៤៥.៨៣១,៨ លានរៀល (១១,១ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៦ ត្រូវបានបញ្ជាក់ជាតម្លៃថេរនៃឆ្នាំ២០០០ ។ នៅក្នុងឆ្នាំ២០០៦ ការចំណាយចរន្តលើវិស័យ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្មើនឹង៦,៧ ភាគរយនៃចំណាយចរន្តនៅក្នុងវិស័យអាទិភាព ។

នៅក្នុងឆ្នាំ២០០៦ ការចំណាយចរន្តលើការអភិវឌ្ឍជនបទ មានចំនួន ២៤.២៣៥,១ លានរៀល (៥,៩ លានដុល្លារ ស.រ.អ) ដែលជាការកើនឡើង២២៨ ភាគរយ បើប្រៀបធៀបជាមួយឆ្នាំ២០០០ ។ ចំណែកនៃចំណាយចរន្តសរុបរបស់វិស័យនេះទៅលើវិស័យអាទិភាព គឺ១,៣ ភាគរយនៅក្នុងឆ្នាំ២០០៦ ។

ចំណាយចរន្តលើវិស័យយុត្តិធម៌ បានកើនឡើងដល់៩០ ភាគរយ រវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ ។ ដោយបញ្ជាក់ជាតម្លៃថេរនៃឆ្នាំ២០០០ ចំណាយនេះ គឺស្មើនឹង ៥.៦៨៨,០០ លានរៀល (១,៤ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០០ និងឈានដល់ ១០.៧៨៦,៩ លានរៀល (២,៦ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ ២០០៦ ។ ប៉ុន្តែ ជាចំណែកនៃចំណាយចរន្តអាទិភាពសរុប ចំណាយនេះមានត្រឹមតែ១,៦ ភាគរយប៉ុណ្ណោះ ។

រវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ ការចំណាយចរន្តលើនគរូបនីយកម្ម និងសំណង់ បានកើនឡើង ដល់១៤៤ ភាគរយ ។ ការចំណាយចរន្តរបស់វិស័យនេះ បានកើនឡើងពី ៤.២៥២ លានរៀល (១,១ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០០ ដល់ ១០.៣៦៩,៨ លានរៀល (២,៥ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ ២០០៦ ។ ជាចំណែកនៃចំណាយចរន្តអាទិភាពសរុបចំណាយនេះមានត្រឹមតែ១,៥ភាគរយ ប៉ុណ្ណោះ ។

វាជាការគួរឱ្យភ្ញាក់ផ្អើល ដែលឃើញនិន្នាការអវិជ្ជមាននៅក្នុងការចំណាយចរន្តនៃវិស័យ កិច្ចការ

| តារាង ៤.១ : ចំណាយចរន្ត ២០០០-២០០៦ ជាចំណែកនៃចំណាយចរន្តសរុប | | | | | | | |
|---|---|---|---|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
| ចំណាយសរុប តាមក្រសួង | ១០០% | ១០០% | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| រដ្ឋបាលទូទៅ (មិនរាប់បញ្ចូលយុត្តិធម៌) | ២២,៣ | ១៨,៦ | ១៨,៧ | ២២,៣ | ១៦,៧ | ១៧,៥ | ១៧,៤ |
| ការពារជាតិ និងសន្តិសុខ | ៣៧,២ | ២៩,៥ | ២៥,៨ | ២៣,៤ | ២៤,២ | ២២,៩ | ២១,៩ |
| វិស័យផ្សេងៗ | ៩,៩ | ២០,០ | ១៨,០ | ១៩,១ | ២០,៣ | ២៥,៣ | ២៥,៤ |
| វិស័យអាទិភាពសរុប | ៣០,៦ | ៣១,៩ | ៣៧,៥ | ៣៥,២ | ៣៨,៨ | ៣៤,៣ | ៣៥,៣ |
| អប់រំ | ១៤,៨ | ១៤,៨ | ១៨,៤ | ១៧,១ | ១៨,៧ | ១៧,៨ | ១៨,៨ |
| សុខភាពសាធារណៈ | ៧,៩ | ៩,២ | ១០,៤ | ៩,៨ | ១១,០ | ១១,៤ | ១១,៣ |
| កិច្ចការនារី | ៤,៥ | ៤,២ | ៤,១ | ៤,១ | ៤,៩ | ០,៥ | ០,៦ |
| កសិកម្ម | ១,៩ | ២,២ | ២,៥ | ២,២ | ២,២ | ២,៤ | ២,៤ |
| អភិវឌ្ឍន៍ជនបទ | ០,៦ | ០,៩ | ១,២ | ១,០ | ១,០ | ១,១ | ១,៣ |
| យុត្តិធម៌ | ០,៥ | ០,៤ | ០,៥ | ០,៦ | ០,៦ | ០,៦ | ០,៦ |
| នគរូបនីយកម្ម និងសំណង់ | ០,៤ | ០,៣ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៥ |

ប្រភព: *គណនាផ្អែកទៅលើការអនុវត្តថវិកាឆ្នាំ២០០០-២០០៦នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

នារី ។ រវាងឆ្នាំ២០០០ និងឆ្នាំ២០០៦ ការចំណាយចរន្តរបស់វិស័យកិច្ចការនារី ត្រូវបានកាត់បន្ថយយ៉ាងខ្លាំងដល់៨០ ភាគរយ ។ ចំណាយនេះ គឺ ៥២.៨៧៩ លានរៀល (១៣,៥ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ ២០០០ ប៉ុន្តែ មានត្រឹមតែ ១០.៧០៣,៧ លានរៀល (២,៦ លានដុល្លារ ស.រ.អ) ប៉ុណ្ណោះនៅក្នុងឆ្នាំ ២០០៦ ដែលស្មើនឹង១,៦ ភាគរយ នៃចំណាយចរន្តអាទិភាពសរុប ។

## ៤.២.២ ចំណាយមូលធន ( ច្បាប់ថវិកា)

ចំណាយមូលធន ជាទូទៅត្រូវបានមើលឃើញថាជាកត្តាជំរុញដ៏ចំបងនៃការអភិវឌ្ឍ ។ មានប្រភពនៃមូលនិធិពីរសម្រាប់ចំណាយមូលធន : ហិរញ្ញប្បទានពីខាងក្រៅ និងហិរញ្ញប្បទានក្នុងស្រុក ។ ហិរញ្ញប្បទានពីខាងក្រៅ គឺជាប្រភពដ៏ចំបងដែលស្មើនឹង៧៥,២ ភាគរយនៃចំណាយមូលធនសរុបនៅក្នុងឆ្នាំ ២០០៤ និង៧២,៩ ភាគរយនៅក្នុងឆ្នាំ២០០៦ ។ ទោះជាយ៉ាងណាក៏ដោយ ដូចបានពោលខាងដើម នៅថ្នាក់ក្រសួង យើងទទួលបានតែទិន្នន័យស្តីពីចំណាយមូលធនដែលជាហិរញ្ញប្បទានក្នុងស្រុកតែ

**រូបភាព ៤.៤ ៖ ចំណែកនៃថវិកាមូលធន ៖ វិស័យអាទិភាព ធៀបនឹងវិស័យមិនមែនអាទិភាព២០០០-២០០៦ (%)**




**ប្រភព៖** *គណនាផ្អែកទៅលើការអនុវត្តថវិកាឆ្នាំ២០០០-២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ប៉ុណ្ណោះ និងត្រឹមតែពីឆ្នាំ២០០៤ ប៉ុណ្ណោះ ។ ជាលទ្ធផលយើងនឹងវិភាគលើនិន្នាការនៃចំណាយមូលធន ដោយផ្អែកលើច្បាប់ថវិកា និងមិនផ្អែកលើការអនុវត្តថវិកាទេ (ដូចនៅក្នុងផ្នែកចំណាយចរន្ត ដែលមានទិន្នន័យស្ដីពីការអនុវត្តថវិកា) ។

ការបង្កើនចំណាយមូលធន ដោយសង្កត់ធ្ងន់លើវិស័យអាទិភាព គឺជាគោលបំណងនៃគោលនយោបាយ សារពើពន្ធគាំទ្រជនក្រីក្ររបស់រាជរដ្ឋាភិបាល ។ ទោះបីជាមានការកើនឡើងក្នុងរយៈពេលពីឆ្នាំ២០០០-២០០៦ ទាំងមូលក៏ដោយ និន្នាការអវិជ្ជមានមួយអាចត្រូវបានមើលឃើញនៅក្នុងរូបភាពទី៤.៤ ខាងក្រោម ដែលចំណែកនៃថវិកាមូលធនសម្រាប់វិស័យអាទិភាពបានបន្តធ្លាក់ចុះចាប់តាំងពីឆ្នាំ២០០១ លើកលែងតែឆ្នាំ២០០៤ ។

ទិន្នន័យនៅក្នុងតារាង ៤.២ ខាងក្រោម និងឧបសម្ព័ន្ធ៤ បង្ហាញយ៉ាងច្បាស់ថា គ្មាននិន្នាការស៊ីសង្វាក់គ្នា នៅក្នុងចំណាយមូលធនថវិកានៅក្នុងវិស័យអាទិភាពទេ ទោះបីជាគេសង្កេតឃើញមានការកើនឡើងក្នុងរយៈពេល ពីឆ្នាំ២០០០-២០០៦ ក៏ដោយ ។ ឧទាហរណ៍ វិស័យអាទិភាពត្រូវបានបែងចែកលុយតិចនៅក្នុងអាណត្តិទាំងពីរចំនួនសរុប និងជាចំណែកនៃចំណាយមូលធនសរុប ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៦ ។ នៅក្នុងឆ្នាំ២០០១ ថវិកា មូលធនសម្រាប់វិស័យអាទិភាព គឺ ៧៩៧.៣៥២ លានរៀល (២០២.៨ លានដុល្លារ ស.រ.អ) ប៉ុន្តែចំនួននេះបានធ្លាក់ចុះមកនៅត្រឹម ៤៧៦.១៣១ លានរៀល (១១៦ លានដុល្លារ ស.រ.អ) ប៉ុណ្ណោះនៅក្នុងឆ្នាំ២០០៦ ។ ទាក់ទងនឹងថវិកាមូលធនសរុបបានធ្លាក់ចុះជិតដប់ចុចភាគរយក្នុងរយៈពេលនេះ ពី៤១,២ ភាគរយមកនៅត្រឹម ៣២,៥ភាគរយ ។

| តារាង ៤.២ : ចំណាយមូលធននៃច្បាប់ថវិកា ២០០០-២០០៦ ចំណែកនៃថវិកាមូលធនសរុប | | | | | | | |
|---|---|---|---|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
| ថវិកាមូលធនសរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| វិស័យផ្សេងៗ | ៧១,៣ | ៥៨,៨ | ៦២,៤ | ៦៥,១ | ៥៨,៧ | ៦៤,៦ | ៦៧,៥ |
| វិស័យអាទិភាពសរុប | ២៨,៧ | ៤១,២ | ៣៧,៦ | ៣៤,៩ | ៤១,៣ | ៣៥,៤ | ៣២,៥ |
| អប់រំ | ៩,៩ | ៧,៩ | ៦,០ | ៨,៤ | ៩,៦ | ១១,៩ | ៨,២ |
| សុខភាពសាធារណៈ | ១៩,៩ | ២៣,២ | ២០,៨ | ២០,២ | ២៣,២ | ១៩,៥ | ១៨,៨ |
| កិច្ចការនារី | ១,៨ | ១,៤ | ១,៣ | ១,៧ | ៤,១ | ២,៩ | ៣,៤ |
| កសិកម្ម | ០,៩ | ៦,៧ | ៩,៦ | ៨,៤ | ៩,៩ | ៨,០ | ៦,០ |
| អភិវឌ្ឍន៍ជនបទ | ៤,៩ | ៩,១ | ៥,១ | ៣,៧ | ៣,២ | ៣,៧ | ៣,៥ |
| យុត្តិធម៌ | ០,៨ | ០,៤ | ០,៤ | ០,២ | ០,២ | ០,៥ | ០,២ |
| នគរូបនីយកម្ម និងសំណង់ | ០,៤ | ០,៤ | ០,៣ | ០,៦ | ០,៧ | ០,៨ | ០,៧ |

ប្រភព : *គណនាផ្អែកទៅលើការអនុវត្តថវិកាឆ្នាំ២០០០-២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## ៤.៣ និន្នាការនៅក្នុងការសងការប្រាក់ និងការសងរំលស់បំណុល

និន្នាការក្នុងការសងការប្រាក់ និងការសងរំលស់បំណុល គឺគួរឱ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ដូចបានបង្ហាញនៅក្នុងតារាងទី៤.៣ ការសងការប្រាក់បានកើនឡើងលើសពីពីរដងជាតម្លៃពិតពី២០ ពាន់លានរៀល (៥,១ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០០ ដល់៤០,៨ ពាន់លានរៀល (៩,៩ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ ២០០៦ ។ ការសងបំណុលបានចាប់ផ្ដើមនៅក្នុងឆ្នាំ២០០១ ជាមួយនឹងទឹកប្រាក់ ៤ពាន់លានរៀល (១ លានដុល្លារ ស.រ.អ) ។ ការសងរំលស់បំណុលបានកើនឡើងលើសពី១០ដង ដល់៤៥ ពាន់លានរៀល (១១លាន ដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៦ ដោយស្មើនឹង១៤.៥ ភាគរយនៃចំណាយមូលធនដែលផ្ដល់ហិរញ្ញប្បទានក្នុងស្រុក ។ បើពិចារណាលើស្ថានភាពបច្ចុប្បន្ន ដែលទំហំនៃប្រាក់កម្ចីពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីនៅតែបន្តកើនឡើង និន្នាការនេះទំនងដូចជានឹងបន្តកើនឡើងជាច្រើនឆ្នាំខាងមុខទៀត ។ និន្នការនេះគួរតែត្រូវបានមើលឃើញជាកង្វល់មួយសម្រាប់ការធ្វើវិភាជន៍ធនធានរបស់រដ្ឋាភិបាលនៅពេលអនាគត ពីព្រោះការសងការប្រាក់ និងការសងបំណុល គឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាល ហើយការចំណាយផ្សេងទៀតអាចបែងចែកបានតែនៅពេលដែលកាតព្វកិច្ចនេះត្រូវបានបំពេញរួចរាល់ប៉ុណ្ណោះ ។ នេះមានន័យថា ការបង្កើននូវការសងការប្រាក់ និងការសងបំណុលនឹងដាក់កំហិតលើសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបំពេញតម្រូវការនៃការអភិវឌ្ឍផ្សេងទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការវិភាគបំណុលរបស់ខ្លួន អង្គការ IMF បានសន្និដ្ឋានថា បំណុល

| តារាង ៤.៣ : និន្នាការក្នុងការសងរំលស់បំណុល និងការសងការប្រាក់២០០០-២០០៦ | | | | | | | |
|---|---|---|---|---|---|---|---|
| ឆ្នាំ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
| ចំណាយមូលធន | ៨៨៧.០ | ១០៧៣.១ | ១៣៤២.៨ | ១១១២.៨ | ១០៨១.៧ | ១១៣៤.២ | ១១៤៦.៤ |
| ហិរញ្ញប្បទានក្នុងស្រុក | ៣០៩.០ | ២៧៥.៨ | ៣២៧.០ | ៣១៦.៥ | ២៦៨.៤ | ២៦៩.៥ | ៣១១.០ |
| ហិរញ្ញប្បទានពីបរទេស | ៥៧៨.០ | ៧៩៧.៣ | ១០១៥.៨ | ៧៩៥.៤ | ៨១២.៤ | ៨៦៤.៧ | ៨៣៥.៤ |
| ការសងបំណុល | | ៣.៩ | ៧.៧ | ៥៦.១ | ២២.៧ | ៣២.២ | ៤៥.០ |
| *បំណុល/ចំណាយមូលធនដែលជាហិរញ្ញប្បទានក្នុងស្រុក* | *0,0%* | *១,៤%* | *២,៤%* | *១៧,៧%* | *៨,៤%* | *១១,៩%* | *១៤,៥%* |
| ចំណាយចរន្ត | ១,១៧៧ | ១៣៨០,១ | ១៥២៣,៧ | ១៦៧០,៧ | ១៥៨២,២ | ១៦៨១,៣ | ១៩៣១,៩ |
| ការសងការប្រាក់ | ២០,០ | ២១,៤ | ២៧,១ | ៣២,៣ | ៤៤,៤ | ៤៧,២ | ៤០,៨ |
| ការសងការប្រាក់/ចំណាយចរន្តសរុប | ១,៧% | ១,៦% | ១,៨% | ១,៩% | ២,៨% | ២,៨% | ២,១% |

**សំគាល់ :** តម្លៃជាពាន់លានរៀល នៅក្នុងតម្លៃថេរនៃឆ្នាំ២០០០ ។

**ប្រភព :** *គណនាផ្អែកទៅលើការអនុវត្តថវិកាឆ្នាំ២០០០-២០០៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

របស់កម្ពុជានៅតែ អាចទ្រាំទ្របាននៅឡើយ (សូមមើល ផ្នែក ៤.៥ សម្រាប់សេចក្តីលំអិត) ។

## ៤.៤ វិមជ្ឈការ និងថវិកា

វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ត្រូវបានមើលឃើញថាជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការបន្តជំរុញរដ្ឋាភិបាលតាមបែបលទ្ធិប្រជាធិបតេយ្យ បន្ថែមលើការលើកកំពស់អភិបាលកិច្ចល្អ និងការកែលំអការផ្តល់សេវា ។ ការអនុម័តច្បាប់នៅក្នុងឆ្នាំ២០០១ ដើម្បីជំនួសអាជ្ញាធរមូលដ្ឋានដែលត្រូវបានតែងតាំងជាមួយក្រុម ប្រឹក្សាឃុំដែលត្រូវបានជ្រើសតាំងដោយផ្ទាល់ បានបង្កើតនូវយន្តការមួយសំដៅអោយមានការចូលរួមដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ចមូលដ្ឋាន និងពង្រឹងបន្ថែមលើគោលការណ៍នៃការទទួលស្គាល់ (គណនេយ្យភាព) របស់រដ្ឋាភិបាលថ្នាក់ក្រោមចំពោះប្រជាពលរដ្ឋ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ នៅក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៧ និងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំបន្តិចម្តងៗ គូសបញ្ជាក់អំពីការផុសឡើងនៃរចនាសម្ព័ន្ធដែលមាននិរន្តរភាពនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់សិទ្ធិអំណាចផ្នែកគ្រប់គ្រង និងហិរញ្ញវត្ថុដល់អាជ្ញាធរមូលដ្ឋាន នៅតែមានចំណុចសម្រាប់ការកែលំអឈានទៅរកប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាពនៅឡើយ ។

មាត្រា១៤៦នៃរដ្ឋធម្មនុញ្ញផ្តល់នូវមូលដ្ឋានច្បាប់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដោយមានបញ្ញត្តិសម្រាប់ការអនុម័តច្បាប់អង្គការ ដែលនៅតែមិនទាន់ត្រូវបានបញ្ចប់នៅឡើយ ។ច្បាប់អង្គការនេះ ត្រូវ

បានរំពឹងថា នឹងពន្យល់បានច្បាស់លាស់អំពីតួនាទី និងទំនាក់ទំនងរបស់ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ និង ឃុំ/សង្កាត់ ដើម្បីបែងចែក ឱ្យបានច្បាស់លាស់រវាងរចនាសម្ព័ន្ធអភិបាលកិច្ចជនបទ និងក្រុង និងផ្តល់ នូវមូលដ្ឋានច្បាប់សម្រាប់ការបែងចែក មុខងារ និងប្រាក់ចំណូលទៅឱ្យអង្គភាពថ្នាក់ក្រោមជាតិ ។ ក្រៅ ពីនេះបញ្ហាសំខាន់ៗមួយចំនួនផ្សេងទៀត នៅតែត្រូវការដោះស្រាយអោយបានប្រសើរឡើង : ការ លើកកំពស់តម្លាភាព និងគណនេយ្យភាពនៅក្នុងយន្តការរដ្ឋបាលមូលដ្ឋាន ធនធានមនុស្សរបស់រដ្ឋបាល មូលដ្ឋាន សមត្ថភាពប្រមូលប្រាក់ចំណូលឃុំ/សង្កាត់ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការធ្វើ សេចក្តីសម្រេចចិត្តព្រមទាំងការអភិវឌ្ឍនៅមូលដ្ឋាន ។

បច្ចុប្បន្ននេះ វិមជ្ឈការត្រូវបានអនុវត្តនៅថ្នាក់ឃុំ/សង្កាត់ គាំទ្រដោយច្បាប់ និងនីតិកម្មជាច្រើន ដូចជាច្បាប់ស្តីពីរដ្ឋបាលគ្រប់គ្រងឃុំ/សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ/ សង្កាត់ ។ ក្រៅពីការផ្តល់សិទ្ធិអំណាចផ្នែកនយោបាយ ក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏ត្រូវបានផ្តល់នូវសិទ្ធិ ធ្វើសេចក្តីសម្រេចចិត្តដែលមានកម្រិតលើការផ្តល់សេវា និងបញ្ហាសារពើពន្ធមួយចំនួនផងដែរ ។ តាម ផ្លូវច្បាប់ ឃុំ/សង្កាត់ មានសិទ្ធិទទួលបានប្រភពប្រាក់ចំណូលបីសំខាន់ៗ : ប្រាក់ចំណូលពីប្រភពផ្ទាល់ខ្លួន មូលនិធិដែលត្រូវបានផ្ទេរពីរដ្ឋបាលកណ្តាល និងប្រាក់បដិភាគ (វិភាគទានមូលដ្ឋាន) ។ រហូតមក ដល់បច្ចុប្បន្ន ច្បាប់ដែលកំណត់អំណាចរបស់ឃុំ/សង្កាត់ក្នុងការបង្កើតប្រាក់ចំណូលផ្ទាល់ខ្លួន មិនទាន់ ត្រូវបានអនុម័តនៅឡើយទេ ហើយថវិការបស់ឃុំ/សង្កាត់ នៅតែពឹងផ្អែកយ៉ាងខ្លាំងលើមូលនិធិដែល ត្រូវបានផ្ទេរពីរដ្ឋបាលកណ្តាលនៅឡើយ ។ ចំនួនទឹកប្រាក់ជាមធ្យម ដែលត្រូវបានផ្ទេរពីរដ្ឋបាល កណ្តាលទៅឱ្យឃុំ/សង្កាត់នីមួយៗ គឺ ៤៨ លានរៀល (១១.៧០០ ដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៦ (Sieng ២០០៦: ១២) ។ នៅក្នុងឆ្នាំ២០០៧ ហិរញ្ញប្បទានដោយផ្ទាល់របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ តាមរយៈមូលនិធិឃុំ/សង្កាត់ មានចំនួនប្រមាណ ២.៦% នៃថវិកា ។ ដោយគ្មានគោលនយោបាយអនុវត្ត ដែលអាចអនុវត្តបានទេនោះ ឃុំ/សង្កាត់ នៅតែទំនងជានឹងមិនអាចបង្កើតប្រាក់ចំណូលបានច្រើនទេ ពីព្រោះពួកគេអាចស្ថិតនៅក្រោមឆន្ទៈនៃថ្នាក់លើរបស់ពួកគេគឺអាជ្ញាធរស្រុក និងខេត្ត ។

សមត្ថភាពឃុំ/សង្កាត់ ក្នុងការបំពេញករណីយកិច្ចសារពើពន្ធ ក៏នៅតែជាកង្វល់ផងដែរ ។ ជាមួយ នឹងសមត្ថភាពធនធានមនុស្ស និងសក្តានុពលសេដ្ឋកិច្ចមានកម្រិតនៅក្នុងសហគមន៍ ភាគរយរបស់ឃុំ/ សង្កាត់តិចតួចប៉ុណ្ណោះ ដែលអាចឈរបានដោយខ្លួនឯង ដោយគ្មានការគាំទ្រពីរដ្ឋបាលកណ្តាល ។ ក្រប ខ័ណ្ឌសារពើពន្ធច្បាស់លាស់ ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពសម្រាប់បុគ្គលិកឃុំ/សង្កាត់ គឺ ជាការសំខាន់ឱ្យប្រព័ន្ធនេះមានដំណើរការ ។

## ៤.៥ បំណុលសាធារណៈ

សេដ្ឋកិច្ចកម្ពុជា ទទួលបាននូវកំណើនលេខពីរខ្ទង់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ។ ទោះជាយ៉ាង ណាក៏ដោយ ប្រាក់ចំណូលដែលប្រមូលដោយរដ្ឋាភិបាលនៅតែមានកម្រិតទាបនៅឡើយ បើប្រៀបធៀប ជាមួយការចំណាយរបស់ខ្លួន ដោយបណ្តាលឱ្យមានឱនភាពថវិកាដ៏ធំធេងជារៀងរាល់ឆ្នាំ ។ ជាលទ្ធ ផលថវិកានៅតែពឹងផ្អែកយ៉ាងខ្លាំងលើហិរញ្ញប្បទានពីខាងក្រៅទាំងជំនួយឥតសំណង ទាំងប្រាក់កម្ចី ដោយធ្វើឱ្យបំណុលរបស់ប្រទេសមានការកើនឡើង ។

យោងតាមអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (ឆ្នាំ២០០៦) បំណុលជាតិរបស់កម្ពុជា បានឈានដល់៣.៣៩១ លានដុល្លារ ស.រ.អ (១៣.៩២៦,៨ ពាន់លានរៀល) រួចទៅហើយ ។ បំណុលពីខាងក្រៅស្មើនឹង ៣.១៨២ លានដុល្លារ ស.រ.អ (១៣.០៦៨,៤ ពាន់លានរៀល) ឬ ៩៤ ភាគរយ ហើយបំណុលក្នុងស្រុក គឺ ២១០ លានដុល្លារ ស.រ.អ (៨៦២.៤ ពាន់លានរៀល)។ ចំនួននៃបំណុលនេះ ស្មើនឹង ៥៤ភាគរយនៃផលិតផលសរុបក្នុងស្រុក (GDP) រួចទៅហើយ ។

**តារាង ៤.៤ : បំណុលសាធារណៈដែលនៅមិនទាន់សង២០០៥ គិតជាដុល្លារ ស.រ.អ (លាន)**

| | |
|---|---|
| **បំណុលខាងក្រៅ** | **៣.១៨០** |
| ពហុភាគី | ១.១៤៩ |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៨១ |
| ជំនួយអភិវឌ្ឍន៍អន្តរជាតិ (IDA) | ៤៦១ |
| ជំនួយអភិវឌ្ឍន៍អាស៊ី (ADB) | ៥៦៨ |
| ទ្វេភាគី | ២.០៣១ |
| រុស្ស៊ី | ១.៥២៥ |
| សហរដ្ឋអាមេរិក | ៣០២ |
| **បំណុលក្នុងស្រុក** | **២១០** |
| **សរុប** | **៣.៣៩១** |

**ប្រភព:** *IMF 2006*

ប្រមាណ៣៤ ភាគរយនៃបំណុលខាងក្រៅ គឺជំពាក់ឥណទាយកពហុភាគី ពោលគឺ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) ។ សហរដ្ឋអាមេរិក និងសហព័ន្ធរុស្ស៊ី គឺជាឥណទាយកធំជាងគេពីរ ដែលគ្របដណ្តប់លើបំណុលប្រមាណ៦៤ ភាគរយនៃបំណុលខាងក្រៅសរុបរបស់កម្ពុជា ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា មិនបានសងការប្រាក់លើបំណុលរបស់ខ្លួនទេ ហើយកំពុងចរចាជាមួយប្រទេសទាំងពីរនេះតាមរយៈកិច្ចព្រមព្រៀងក្របខ័ណ្ឌក្លឹបប៉ារីស ដើម្បីរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ។ ការចរចាជាមួយសហរដ្ឋអាមេរិក ភាគច្រើនគឺនិយាយអំពីចំនួនប្រាក់ដើម ។ ឥឡូវនេះ ភាគីទាំងពីរបានឈានដល់ការព្រមព្រៀងលើចំនួនប្រាក់ដើមសរុប ដែលត្រូវសង គឺ ១៦២ លានដុល្លារ ស.រ.អ (៦៦៥,៣ ពាន់លានរៀល)។ ជាមួយសហព័ន្ធរុស្ស៊ី ការចរចានិយាយអំពីអត្រាប្តូរប្រាក់រវាងរូបិយវត្ថុរុស្ស៊ីរូប៊ិល និងដុល្លារ ស.រ.អ ។ រហូតមកដល់ពេលនេះ ប្រទេសរុស្ស៊ី បានយល់ព្រមកាត់បន្ថយ៧០ភាគរយ នៃបំណុល ពី ១,៥២ ពាន់លានដុល្លារ ស.រ.អ (៦.២៤២,៦ ពាន់លានរៀល) មកនៅត្រឹម ៤៥៧ លានដុល្លារ ស.រ.អ (១.៨៧៦,៩ ពាន់លានរៀល)។ ជាមួយលទ្ធផលនេះ ដូចអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) (2007) ប្រាប់យើង បំណុល

សាធារណៈខាងក្រៅសរុបរបស់កម្ពុជា ត្រូវបានកាត់បន្ថយមកនៅត្រឹម ២,២៥ ពាន់លានដុល្លារ ស.រ.អ (៩.២៥៨,៧ ពាន់លានរៀល) ឬ៣១ភាគរយនៃផលទុនក្នុងស្រុកសរុប ។ ផលធៀបនេះ ត្រូវបានបង្ហាញថា នឹងមានការថយចុះបន្ថែមទៀតនៅក្នុងឆ្នាំ២០០៧ ។

ផ្អែកលើការវិភាគនេះ អង្គការIMF និងសមាគមអភិវឌ្ឍន៍អន្តរជាតិ(IDA) របស់ធនាគារពិភពលោក (2007) បានសន្និដ្ឋានថា ស្ថានភាពបំណុលរបស់កម្ពុជា ស្ថិតនៅលើផ្លូវដែលមាននិរន្តរភាពនៅឡើយ ។ នៅក្នុងរបាយការណ៍ Article IV Report ឆ្នាំ២០០៦ របស់ខ្លួន អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានសន្និដ្ឋានថា បំណុលរបស់កម្ពុជា កំពុងប្រឈមនឹងគ្រោះថ្នាក់ខ្លាំង ។ គ្រោះថ្នាក់ត្រូវបានកាត់បន្ថយមកត្រឹមកម្រិតមធ្យមនៅឆ្នាំនេះ ដោយសារកំណើនផលទុនក្នុងស្រុកសរុបខ្ពស់ជាងការរំពឹងទុក និងហិរញ្ញប្បទានសម្បទានទ្រង់ទ្រាយធំ ដែលមានជាបន្តពីដៃគូអភិវឌ្ឍន៍ជាប្រពៃណី និងដៃគូអភិវឌ្ឍន៍ថ្មី ដែលត្រូវបានប្រើដើម្បីពន្យល់ហេតុផលអំពីការកាត់បន្ថយគ្រោះថ្នាក់ដោយសារបំណុល ។

ថ្មី១នេះ កម្ពុជាបានទទួលពិន្ទុឥណទានអធិបតេយ្យ B+ ដោយ Standard and Poor’s និង B2 BI Moody’s ។ យោងតាមរបាយការណ៍ស្តីពីបុគ្គលិករបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ២០០៧ នេះអាចផ្តល់ឱកាសមួយសម្រាប់ការខ្ចីប្រាក់ផ្នែកពាណិជ្ជកម្ម ។ ទោះជាយ៉ាងណាក៏ដោយ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏ព្រមានផងដែរថា និរន្តរភាពបំណុលអាចជាគ្រោះថ្នាក់ដ៏ធំជាងនេះ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាខ្ចីប្រាក់ក្រោមលក្ខខណ្ឌពាណិជ្ជកម្ម ។

ដូចបានបង្ហាញខាងលើ រាជរដ្ឋាភិបាលកម្ពុជា មិនទាន់សងការប្រាក់លើបំណុលរបស់ខ្លួនទៅឱ្យឥណទាយកធំ១ពីរនៅឡើយទេ ។ ប៉ុន្តែ ប្រសិនបើ យើងពិនិត្យមើលការអនុវត្តថវិកា យើងអាចឃើញថា ការសងបំណុលខាងក្រៅ បានចាប់ផ្តើមនៅក្នុងឆ្នាំ២០០១ ហើយបាន និងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ។ ការសងបំណុលបានកើនឡើងជិត១៣ ដង ពី ៤ ពាន់លានរៀល (១ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ ២០០១ ដល់ ៥៥,២ ពាន់ លានរៀល (១៣,៤ លានដុល្លារ ស.រ.អ) នៅក្នុងឆ្នាំ២០០៦ ។ ការសងការប្រាក់ក៏បានកើនឡើងផងដែរ ក្នុងរយៈពេលនេះ ពី ២២ ពាន់លានរៀល (៥,៦ លានដុល្លារ ស.រ.អ) ដល់៥០ ពាន់លានរៀល (១២,១ លានដុល្លារ ស.រ.អ) ។

# ៥ បញ្ហាដែលពាក់ព័ន្ធ

## ៥.១ ការទទួលបានព័ត៌មានស្តីពីថវិកា

ការទទួលបានព័ត៌មានស្តីពីថវិកា គឺជាការសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាដែលជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ។ ជាមួយនឹងការទទួលបានព័ត៌មានស្តីពីថវិកាដែលល្អប្រសើរ ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមបានច្រើន ឧទាហរណ៍ ក្នុងការត្រួតពិនិត្យតាមដានការអនុវត្តថវិកា ហើយឱ្យរដ្ឋាភិបាលទទួលខុសត្រូវ និងជួយលើកកំពស់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អ ។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ថាការទទួលបានព័ត៌មានស្តីពីថវិកាគឺជាការសំខាន់ ហើយបានធ្វើការប្តេជ្ញាចិត្តលើកកំពស់ការទទួលបានព័ត៌មានអំពីថវិកា ។ ក្រោមកម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របាយការណ៍បច្ចុប្បន្នភាពប្រចាំខែស្តីពីភាពជឿនលឿននៃការអនុវត្តថវិកា រាប់បញ្ចូលទាំងការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំដ៏គ្រប់ជ្រុងជ្រោយមួយ ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ។ មិនតែប៉ុណ្ណោះ កម្មវិធីនេះ គូសបញ្ជាក់ថា របាយការណ៍ពីអាជ្ញាធរជាតិសវនកម្ម នឹងត្រូវបានផ្សព្វផ្សាយដល់សាធារណជន ។

ទោះជាយ៉ាងណាក៏ដោយ កម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនបានផ្តល់នូវពេលវេលាច្បាស់លាស់ថា តើការប្តេជ្ញាចិត្តទាំងនេះនឹងត្រូវសម្រេចបាននៅពេលណាទេ ។ បច្ចុប្បន្នការទទួលបានព័ត៌មាន និងការប្រាស្រ័យទាក់ទងគ្នានៅមានកម្រិតនៅឡើយ ហើយកម្រិតនៃសេចក្តីលំអិតដែលត្រូវបានផ្តល់ឱ្យអំពីថវិកាជាតិ ក៏នៅមានកម្រិតដែរ ។ រាជរដ្ឋាភិបាលកម្ពុជា បានផលិត និងចងក្រងឯកសារព័ត៌មានដែលទាក់ទងនឹងថវិកាជាច្រើនប្រភេទ ប៉ុន្តែ ឯកសារទាំងអស់នោះពុំសុទ្ធតែត្រូវបានផ្សព្វផ្សាយឱ្យសាធារណជនបានដឹងឡើយ ។ ឯកសារដែលមានព័ត៌មានស្តីពីថវិកា និងដែលត្រូវបានផ្សព្វផ្សាយឱ្យសាធារណជនដឹងគឺច្បាប់ថវិកាជាតិសម្រាប់ការគ្រប់គ្រងនិងច្បាប់ស្តីពីការទូទាត់ថវិកា ។ ឯកសារទាំងពីរនេះត្រូវបានផ្សព្វផ្សាយឱ្យសាធារណជនដឹង តែនៅក្រោយពេលដែលព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើប្រាស់ប៉ុណ្ណោះ ។ ខាងក្រោមនេះ យើងនឹងឃើញការពិពណ៌នាអំពីឯកសារដែលទាក់ទងនឹងថវិកាផ្សេងៗគ្នា ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ អ្នកដែលពាក់ព័ន្ធក្នុងការផលិត និងទីកន្លែងដែលអាចរកឯកសារទាំងនេះបាន[៨] ។

*[៨] ឯកសារដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈទាំងអស់ អាចរកបានពីគម្រោងតាមដានថវិការបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ។*

## ៥.១.១ ឯកសារថវិកា ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ

ច្បាប់ថវិកាជាតិ គឺជាឯកសារដ៏សំខាន់បំផុត ដែលមានព័ត៌មានអំពីថវិកា ត្រូវបានផ្សព្វផ្សាយដល់សាធារណជន ។ នៅកម្ពុជា ច្បាប់ថវិកាជាតិត្រូវបានរៀបចំឡើងសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋនៅក្នុងឆ្នាំខាងមុខ ។ ក្រៅពីតួលេខដែលបង្ហាញពីចំនួនទឹកប្រាក់ ដែលបានធ្វើផែនការសម្រាប់ការប្រមូលកៀងគរប្រាក់ចំណូល និងការចំណាយថវិកា ដែលត្រូវបានបែងចែកសម្រាប់វិស័យនីមួយៗ ច្បាប់នេះក៏មានកំណត់បង្ហាញពន្យល់បរិបទព្រាង និងវិសោធនកម្មណាមួយ ឬមាត្រាថ្មីនៃច្បាប់ហិរញ្ញវត្ថុឆ្នាំ១៩៩៣ ផងដែរ ។

ច្បាប់ថវិកា ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្លងដោយរដ្ឋសភា អនុម័តដោយព្រឹទ្ធសភា និងប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ ។ នៅពេលដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ (នៅចុងខែធ្នូនៃឆ្នាំនីមួយៗ) ច្បាប់នេះក្លាយជាឯកសារសាធារណៈ និងអាចរកបាននៅ i) បណ្ណាល័យជាតិ ii) បណ្ណាល័យព្រឹទ្ធសភា និង iii) បណ្ណាល័យរដ្ឋសភា ។

ឯកសារគ្រប់គ្រងថវិកា ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់គោលបំណងគ្រប់គ្រងថវិការដ្ឋ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះពុម្ពផ្សាយនូវឯកសារថវិកាបួនប្រភេទ :

- ការគ្រប់គ្រងថវិកា : បន្ថែមលើច្បាប់ថវិកា ឯកសារនេះផ្តល់នូវទិដ្ឋភាពទូទៅនៃម៉ាក្រូសេដ្ឋកិច្ច និងគោលការណ៍ណែនាំ និងនីតិវិធីផ្សេងៗសម្រាប់ការអនុវត្តថវិកា ។

- ថវិការដ្ឋសម្រាប់ការគ្រប់គ្រងរបស់ "រដ្ឋបាលកណ្តាល": ផ្តល់នូវផែនការលំអិតសម្រាប់ការប្រមូលកៀងគរចំណូលនិងចំណាយដោយឡែកៗពីគ្នាសម្រាប់ក្រសួងអាជ្ញាធរនិងស្ថាប័នរដ្ឋាភិបាលនីមួយៗនៃរដ្ឋបាលកណ្តាល ។

- ថវិការដ្ឋសម្រាប់ការគ្រប់គ្រងរបស់ "មន្ទីរ និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ខេត្ត/ក្រុង": ព័ត៌មានលំអិតស្តីពីចំណូល និងចំណាយរបស់មន្ទីរខេត្ត/ក្រុងពាក់ព័ន្ធ របស់ក្រសួង/អាជ្ញាធរនីមួយៗ ត្រូវបានបង្ហាញនៅក្នុងឯកសារនេះ ។

- ថវិកាខេត្ត/ក្រុងសម្រាប់ការគ្រប់គ្រង : ឯកសារនេះផ្តល់នូវព័ត៌មានស្តីពីចំណូល និងចំណាយ ដែលត្រូវបានរៀបចំជាថវិកាសម្រាប់ខេត្ត/ក្រុងនីមួយៗ ។ឯកសារនេះក៏មានប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(បទបញ្ជាថ្នាក់ក្រសួង) ដែលក្នុងនោះបុគ្គលម្នាក់ៗ/មន្ទីរនីមួយៗដែលទទួលខុសត្រូវចំពោះការអនុវត្តត្រូវបានកំណត់ ។

នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកដ្ឋានថវិកា អាចផ្តល់ឯកសារស្តីពីការគ្រប់គ្រងថវិកាប្រមាណបីខែ ក្រោយពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ថវិកា ។ ឯកសារទាំងនេះអាចរកបាននៅនាយកដ្ឋានថវិកានៅក្នុងខែមីនា/មេសា ។

ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ត្រូវបានបោះពុម្ពដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ព្រឹត្តិប័ត្រនេះ មានបំណងផ្សព្វផ្សាយព័ត៌មានស្ថិតិស្តីពីផ្នែកសេដ្ឋកិច្ចផ្សេងៗដល់សាធារណជន និងរួមមានតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ (TOFE) ដែលអធិប្បាយអំពីការអនុវត្តចំណូល និងចំណាយមូលធន និងចរន្តជាក់ស្តែងរបស់រដ្ឋ ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យស្ថិតក្នុងកម្រិតសរុប និងមិនមានការបំបែកទៅតាមក្រសួងឡើយ ។

ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ត្រូវបានផលិតដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីរសប្តាហ៍ក្រោយពីរយៈពេលធ្វើរបាយការណ៍បានបញ្ចប់ និងត្រូវបានបង្ហោះតាមវេបសាយភ្លាមបន្ទាប់ពីនោះ ។ ព្រឹត្តិប័ត្រនេះអាចរកបាននៅក្នុងវេបសាយ http://www.mef.gov.kh នៅក្នុងផ្នែក "ការបោះពុម្ពផ្សាយ" ។

ច្បាប់ស្តីពីការទូទាត់ថវិកា អធិប្បាយអំពីចំណូលជាក់ស្តែងដែលរកបាន និងចំណាយពិតនៅក្នុងឆ្នាំសារពើពន្ធមុន ប្រៀបធៀបជាមួយសំណើដើម ។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់នេះ មិនបានពន្យល់អំពីកម្រិតពេលអនុម័តនិងលទ្ធផលជាក់ស្តែងនៃចំណាយនិងរបៀបដែលលុយត្រូវបានចំណាយទេ ។ ច្បាប់ទូទាត់ថវិកា ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្លងដោយរដ្ឋសភា អនុម័តដោយព្រឹទ្ធសភា និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ ។

បច្ចុប្បន្ននេះ នៅក្នុងឆ្នាំ២០០៧ ច្បាប់ទូទាត់ថវិកាថ្មីៗបំផុត ដែលមានសម្រាប់សាធារណជន គឺច្បាប់ពី ឆ្នាំ២០០៤ ។ នៅពេលដែលច្បាប់ទូទាត់ថវិកា ត្រូវបានប្រកាសឱ្យប្រើប្រាស់ (ក្នុងករណីនេះ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៤) ច្បាប់នេះក្លាយជាឯកសារសាធារណៈ ហើយអាចរកបាននៅ i) បណ្ណាល័យជាតិ ii) បណ្ណាល័យព្រឹទ្ធសភា និង iii) បណ្ណាល័យរដ្ឋសភា ។

### ៥.១.២ ឯកសារថវិកាដែលមិនអាចរកបានជាសាធារណៈ

ឯកសារដែលទាក់ទងនឹងថវិកាមួយចំនួននៅកម្ពុជាត្រូវបានផលិត ប៉ុន្តែមិនអាចរកបានជាសាធារណៈទេ ។ ឯកសារទាំងនេះរួមមាន ៖

សារាចរណែនាំស្តីពីថវិកាដំបូង ផ្តល់នូវចំនួនសរុបនៃម៉ាក្រូសេដ្ឋកិច្ច ដែលបង្ហាញអំពីការព្យាករណ៍ចំណូល និងការប៉ាន់ស្មាននៃធនធាន ដែលមានសម្រាប់ឆ្នាំខាងមុខ ។ សារាចរណែនាំនេះ ត្រូវបានផលិតដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងខែឧសភា/មិថុនា ។

តួលេខប្រចាំខែស្តីពីការអនុវត្តថវិកាផ្តល់នូវព័ត៌មានលំអិតស្តីពីចំណូល និងចំណាយរបស់រដ្ឋ ទៅតាមក្រសួង/ស្ថាប័ន ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ ផ្តល់នូវទិដ្ឋភាពទូទៅនៃភាពខុសគ្នារវាងចំណាយដែលបានធ្វើផែនការ និងចំណាយជាក់ស្តែងក្នុងអំឡុងឆ្នាំ និងគួរតែបញ្ចូលសកម្មភាពកែលំអ ប្រសិនបើផែនការអនុវត្តត្រូវបានគំរាមកំហែង ឧទាហរណ៍ ដោយការអនុវត្តមិនល្អនៃលំហូរចំណូល និងការកើតឡើងនៃតម្រូវការសម្រាប់ចំណាយបន្ថែមដែលមិនបានរំពឹងទុក ។ ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ ត្រូវបាន

ធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងខែកក្កដា ។

របាយការណ៍សវនកម្មជាតិ ត្រូវបានផលិតដោយអាជ្ញាធរសវនកម្មជាតិជារៀងរាល់ឆ្នាំ ប៉ុន្តែ ត្រូវដាក់ជូនរដ្ឋសភា និងរដ្ឋាភិបាល ។ របាយការណ៍នេះ ត្រូវបានមើលឃើញថាជាការសំងាត់ និងមិនសមស្របសម្រាប់ការផ្សព្វផ្សាយជាសាធារណៈឡើយ ។

## ៥.២ ប្រភពចំណូលដែលកំពុងលេចឡើង

ការរុករកប្រេង និងឧស្ម័ននៅលើដែនសមុទ្រកម្ពុជា នាពេលថ្មីៗនេះ និងការបង្ហាញអំពីធនធានរ៉ែដ៏សំបូរបែបនៅក្នុងតំបន់បូព៌ា និងឧត្តរនៃប្រទេសនេះ ធ្វើឱ្យគេមានជំនឿយ៉ាងខ្លាំងថា កម្ពុជានឹងក្លាយជាប្រទេសផលិតប្រេង និងរ៉ែដ៏តូចមួយ ដោយបង្កើននូវចំណូលដ៏ធំដុំរបស់ខ្លួនពីឧស្សាហកម្មទាញយកផលប្រយោជន៍ពីរ៉ែទាំងនេះ ។

### *៥.២.១ ប្រេង និងឧស្ម័ន*

នៅពេលសរសេរឯកសារនេះ ចំនួនប៉ាន់ស្មាននៃទឹកប្រាក់ដែលបានមកពីប្រេង ដែលអាចត្រូវបានទាញយកជាលក្ខណៈពាណិជ្ជកម្ម មិនទាន់មានភាពច្បាស់លាស់នៅឡើយ ដូចគ្នានឹងការប៉ាន់ស្មាននៃពេលវេលា និងទំហំនៃចំណូល ដែលបានរំពឹងទុកសម្រាប់រាជរដ្ឋាភិបាលកម្ពុជាដែរ ។ ប៉ុន្តែ វាច្បាស់ថា លំហូរចូលនឹងមានចំនួនច្រើន បើប្រៀបធៀបជាមួយច្បាប់ថវិកាជាតិបច្ចុប្បន្ន (ឆ្នាំ២០០៧) និងសេណារីយ៉ូចុងក្រោយ ដែលត្រូវបានផ្ដល់ឱ្យនៅក្នុងរបាយការណ៍បុគ្គលិករបស់អង្គការ IMF ឆ្នាំ២០០៧ ដែលបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា អាចទទួលបានប្រាក់ចំណូលរហូតដល់ ១.៧ ពាន់លានដុល្លារ ស.រ.អ នៅក្នុងឆ្នាំ២០២១ ដោយកើនឡើងពី ១៧៤ លានដុល្លារ ស.រ.អនៅក្នុងឆ្នាំ២០១១ ។ តាមតួលេខនេះ វាបង្ហាញច្បាស់ថា នឹងមានផលប៉ះពាល់ធំដុំ ដោយហេតុថាចំណូលរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំ២០០៦ បានកើនឡើងជិតដល់៧១០ លានដុល្លារ ស.រ.អ ។

ចំណូលទាំងនេះគួរតែបានមកពីក្រុមហ៊ុន ដែលបច្ចុប្បន្នទទួលបានការអនុញ្ញាតឱ្យរុករកប្រេងសម្រាប់ប្លុកនៅសមុទ្រទាំងប្រាំមួយ ។ក្នុងចំណោមក្រុមហ៊ុនទាំងនេះ ក្រុមធំដែលដឹកនាំដោយក្រុមហ៊ុន Chevron បានឈានដល់ដំណាក់កាលជឿនលឿនបំផុត ហើយត្រូវបានរំពឹងថានឹងធ្វើការប្រកាសមួយស្ដីពីចំនួនប្រេងដែលអាចចំរាញ់យកបាននៅក្នុងប្លុក "ក" នៅចុងឆ្នាំ២០០៧ ។ ក្រុមហ៊ុនធំផ្សេងទៀត ដែលបានទទួលការអនុញ្ញាតឱ្យរុករកពីអាជ្ញាធរជាតិប្រេងកាតកម្ពុជារួមមានក្រុមហ៊ុននាំមុខសំខាន់ៗដូចតទៅ: MEDCO (ឥណ្ឌូនេស៊ី) Petrotech (ចិន) ក្រុមហ៊ុនប្រេងកាតសិង្ហបុរី PTTEP (ប្រទេសថៃ) Polytech (ចិន) និង CNOOC (ចិន)។ ក្រៅពីតំបន់ប្លុកសមុទ្រដែលគ្មានទំនាស់ទាំងប្រាំមួយនេះ ប្លុកចំនួនបួនដែលស្ថិតក្នុងតំបន់អះអាងថាជាន់គ្នារវាងប្រទេសថៃ និងកម្ពុជា ត្រូវបានរំពឹងថានឹងបង្កើតចំណូលបានកាន់តែច្រើននៅពេលដែលការចរចាបានត្រួសត្រាយផ្លូវសម្រាប់ការរុករក និងការធ្វើអាជីវកម្ម ដោយក្រុមហ៊ុនប្រេងផ្សេងៗគ្នា ។ លើសពីនេះទៀត ចំណូលត្រូវបានរំពឹងថានឹងបានមកពីទីតាំងលើដីគោកដែលមានសក្ដានុពលមួយចំនួននៅកម្ពុជា ។ ប៉ុន្តែ បច្ចុប្បន្ននេះ មានព័ត៌មានតិចតួចបំផុតទាក់ទង

នឹងទីតាំង និងក្រុមហ៊ុនដែលពាក់ព័ន្ធ ។

## ៥.២.២ រ៉ែ

ក្រៅពីប្រេង និងឧស្ម័ន កម្ពុជាមានរ៉ែ និង រ៉ែដែកជាច្រើន ដែលអាចធ្វើអាជីវកម្មនៅក្នុងពេលអនាគតដ៏ខ្លី ។ គេបានមើលឃើញថា មានរ៉ែដែកប្រមាណពី២,៥-៤,៨ លានតោន នៅក្នុងតំបន់ភាគខាងជើងនៃប្រទេស និង៥,២ លានតោនទៀតនៅក្នុងខេត្តកំពង់ធំ ។ លើសពីនេះទៀត មានរ៉ែម៉ង់ហ្គាណែសប្រមាណ ១២០.០០០ តោននៅក្នុងខេត្តកំពង់ធំតែឯង[៩] ។ ក្រៅពីនេះតំបន់ព្រៃសាននៃកម្ពុជា ជាពិសេសខេត្តមណ្ឌលគិរី និងរតនគិរី ត្រូវបានគេជឿថាមានរ៉ែមាស ស្ពាន់ និងបុកស៊ីតយ៉ាងច្រើន ។ បច្ចុប្បន្ននេះក្រុមហ៊ុនអន្តរជាតិប្រាំមួយយ៉ាងតិច មានអាជ្ញាប័ណ្ណរុករកលើតំបន់ធំ៧ នៅក្នុងដំណាក់កាលផ្សេង១នៃការរុករក ។ ក្រុមហ៊ុន BHP Billiton ដោយមាន សម្បទានរុករករ៉ែបុកស៊ីតលើបរិវេណរាប់រយពាន់ហិចតា រំពឹងថានឹងបង្ហើបឱ្យដឹងពីលទ្ធផលនៃការរុករកដំបូងរបស់ខ្លួនត្រឹម ពាក់កណ្តាលឆ្នាំ២០០៨ ។

ដូចគ្នានឹងប្រេង និងឧស្ម័នដែរ ការរុករករ៉ែ នឹងបង្កើតនូវចំនួនប្រាក់ចំណូលដ៏ច្រើនសម្រាប់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសួយសារអាករ និងពន្ធ ។ ប៉ុន្តែ នៅដំណាក់កាលនេះ យើងមិនអាចប៉ាន់ស្មានបានថា តើរាជរដ្ឋាភិបាលនឹងទទួលបានចំណូលប៉ុន្មាននៅឡើយទេ ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សជាច្រើនព្យាករណ៍ថា ចំណូលពីការរុករករ៉ែនឹងមានចំនួនច្រើន ហើយទំនងជានឹងមានរយៈពេលយូរ ( ៣០ ឆ្នាំ) ជាងប្រេង (~ ១៥ ឆ្នាំ) ។

## ៥.២.៣ ការជំពាក់ទាក់ទ័ណ្ឌនៃចំណូលពីឧស្សាហកម្មនិស្សារណកម្ម

តាមការប៉ាន់ស្មាន និងការសន្និដ្ឋានទាំងនេះ ចំណូលពីឧស្សាហកម្មនិស្សារណកម្ម (EIs) ដែលរំពឹងទុករបស់រដ្ឋាភិបាលមានចំនួនធំដុំ និងអាចជាប្រភពចំណូលថ្មីដ៏ចំបងសម្រាប់រដ្ឋ ដែលអាចជួយសម្រួលដល់រដ្ឋាភិបាលបានច្រើន ក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព ប្រសិនបើគ្រប់គ្រងបានត្រឹមត្រូវ ។ រូបភាពទី៥.១ បង្ហាញពីប្រាក់ចំណូលដែលត្រូវបានបង្កើតឡើងដោយឧស្សាហកម្មនិស្សារណកម្ម ដែលនឹងជាប្រភពចំណូលថ្មីរបស់រដ្ឋាភិបាល ផ្នែកផ្គត់ផ្គង់ដល់ថវិកាជាតិ ។ កម្មវិធីអភិវឌ្ឍន៍ដែលគួរមានផលប៉ះពាល់ដោយផ្ទាល់លើការចិញ្ចឹមជីវិតរបស់ប្រជាជន ជាពិសេសជនក្រីក្រ និងសេដ្ឋកិច្ច អាចត្រូវបានមើលឃើញថាជាផ្នែកតម្រូវការ ។ វិធីដើម្បីធានាថា ចំណូលពីឧស្សាហកម្មនិស្សារណកម្ម មានផលប៉ះពាល់លើជនក្រីក្រគឺស្ថិតនៅលើការប្រើប្រាស់ថវិកា ។ ដូច្នេះ ប្រសិនបើថវិកាដែលអាចមានចំនួនច្រើនរបស់រដ្ឋាភិបាលនេះ ត្រូវបានចំណាយដោយត្រឹមត្រូវនោះ ដើម្បីឆ្លើយតបទៅនឹងផ្នែកដែលត្រូវការបំផុត និងការវិនិយោគសាធារណៈ ថវិកានេះនឹងនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់ប្រទេស និងរួមចំណែកចំពោះការសម្រេចគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ដូចបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ រាប់បញ្ចូលទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាប្រកបដោយប្រសិទ្ធភាព ។

---

[៩] *http://www.photius.com.*

ប្រសិនបើការអភិវឌ្ឍ អាចសម្រេចបានប្រេង ឧស្ម័ន និងរ៉ែ អាចចាត់ទុកថាជាការប្រសិទ្ធពរជ័យនៃធនធាន ។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍អន្តរជាតិបង្ហាញអំពីគ្រោះថ្នាក់នៃ "បណ្តាសាធនធាន" ដែលទំនងជានឹងកើតឡើងនៅក្នុងប្រទេសមួយ ដែលចំណូលពីការរុករកធនធានធម្មជាតិមានចំនួនច្រើន ប្រៀបធៀបជាមួយសេដ្ឋកិច្ចរបស់ខ្លួន ។ បណ្តាសាធនធាន អាចមានលក្ខណៈពិសេសមួយចំនួន ដូចជាអំពើពុករលួយ និងការស្វែងរកលាភសក្ការៈ ដែលបង្វែរប្រាក់ចំណូលរបស់ឧស្សាហកម្មនិស្សារណកម្មពីចំណូលរបស់រដ្ឋាភិបាលធ្វើឱ្យវិសមភាពចំណូលកាន់តែយ៉ាប់យ៉ឺន និងធ្វើឱ្យភាពក្រីក្រកាន់តែធ្ងន់ធ្ងរ ដោយធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពនយោបាយ ដោយសារការគ្រប់គ្រងធនធានមិនត្រឹមត្រូវ ។

**រូបភាព ៥.១ : ចំណូលពីប្រេង និងឧស្ម័ន និងការអភិវឌ្ឍ**




ត្រូវ ។ វិធីមួយ ដើម្បីចៀសវាងបណ្តាសាធនធាន គឺត្រូវអនុវត្តគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ដែលមានគោលបំណងបង្កើនតម្លាភាពលើកិច្ចការជំនួញរវាងរដ្ឋាភិបាល និងក្រុមហ៊ុននៅក្នុងឧស្សាហកម្មនិស្សារណកម្ម ។ រាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្ន កំពុងសិក្សាលើគម្រោង EITI ដោយការបង្កើតក្រុមការងារជំនាញមួយ ។ ក្រុមការងារនេះ ត្រូវបានរំពឹងថា នឹងធ្វើអនុសាសន៍ទាក់ទងនឹងការអនុម័តជាផ្លូវការលើគម្រោង EITI នេះត្រឹមពាក់កណ្តាលឆ្នាំ២០០៨ ។

ដោយសារប្រាក់ចំណូលពីឧស្សាហកម្មនិស្សារណកម្ម នឹងមិនស្ថិតស្ថេររហូត វាជាការសំខាន់ដែលត្រូវវិនិយោគ (ឬសន្សំ) ធនធានដោយសមស្រប ដើម្បីឱ្យការចរចានាពេលអនាគត នឹងទទួលបានអត្ថប្រយោជន៍ផងដែរ ។ មានបទពិសោធន៍អន្តរជាតិជាច្រើនស្តីពីការគ្រប់គ្រងចំណូលពីធនធានធម្មជាតិដែលមិនអាចបន្តជាថ្មីបាន (ដូចជាប្រេង ឧស្ម័ន និងរ៉ែ) ។ រាជរដ្ឋាភិបាលកម្ពុជា រដ្ឋសភា និងតំណាងសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ គួររៀបចំការពិភាក្សាជាចំហស្តីពីរបៀបប្រើប្រាស់ចំណូលនេះប្រកបដោយប្រសិទ្ធភាព ដើម្បីអភិវឌ្ឍន៍ប្រទេសប្រកបដោយប្រសិទ្ធភាព ដើម្បីចៀសវាងបណ្តាសាធនធាន និងដើម្បីបង្កើនប្រសិទ្ធពរជ័យធនធានជាអតិបរមា ។

## ឧបសម្ព័ន្ធ ១ សទ្ទានុក្រម

**ការសងរំលស់បំណុល** : ការសងបំណុល គឺជាចំនួនតាមកាលកំណត់ ដែលប្រាក់កម្ចីត្រូវគេសងតាមរូបភាពរំលស់ ។

**ថវិកា** : ជាការប៉ាន់ស្មានដោយរដ្ឋាភិបាល ដែលត្រូវបានអនុម័តដោយរដ្ឋសភានូវចំណូល និងការទទួលប្រាក់ប្រចាំឆ្នាំ និងបរិមាណនៃចំណាយដែលបានកំណត់ និងការចំណាយផ្សេងៗ ។

**ចំណូលមូលធន** : ចំណូលពីការលក់ទ្រព្យមូលធនដែលមិនមែនហិរញ្ញវត្ថុ ដូចជាដីធ្លី ទ្រព្យដែលមិនមែនសម្ភារៈ សម្ភារៈបំរុង និងមុខទំនិញដទៃទៀត ដែលមានអាយុលើសពីមួយឆ្នាំ ។

**ឥណទានជាប់សន្យា** : ពាក្យដែលប្រើនៅក្នុងច្បាប់ថវិកាជាតិកម្ពុជា ដើម្បីគូសបញ្ជាក់ថា ខ្ទង់ថវិកានេះត្រូវបានស្នើសុំមូលនិធិខាងក្រៅពីម្ចាស់ជំនួយ ។ ក្នុងប្រតិបត្តិការឥណទានជាប់សន្យានេះ ជាទូទៅនៅក្រៅថវិកា ។

**វិមជ្ឈការ និងវិសហមជ្ឈការ** : ដំណើរការដែលសិទ្ធិ និងការទទួលខុសត្រូវមួយចំនួន និងធនធានត្រូវបានផ្ទេរពីរដ្ឋបាលថ្នាក់ជាតិទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលត្រូវបានជ្រើសតាំងតាមលទ្ធិប្រជាធិបតេយ្យ និងដែលសេវាសាធារណៈ ត្រូវបានផ្តល់ឱ្យដោយថ្នាក់ក្រោមជាតិកាន់តែច្រើនឡើង ។

**ឱនភាព** : ចំនួនចំណាយលើសចំណូលនៅក្នុងរយៈពេលជាក់លាក់មួយ ។

**ពន្ធដោយផ្ទាល់** : ពន្ធដែលត្រូវបានកំណត់ដោយផ្ទាល់ទៅលើអ្នកបង់ពន្ធ ដូចជាពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណូល ពន្ធលើអំណោយ និងមរតក ។

**ឆ្នាំសារពើពន្ធ** : រយៈពេល១២ ខែដែលរដ្ឋរៀបចំផែនការចំណូល និងចំណាយ ។ នៅកម្ពុជារយៈពេលនេះ ដូចគ្នានឹងឆ្នាំប្រតិទិន (ថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ) ។

**ផលទុនក្នុងស្រុកសរុប (GDP)** : តម្លៃសរុបនៃទំនិញ និងសេវាទាំងអស់ ដែលបានផលិតនៅក្នុងប្រទេសមួយក្នុងអំឡុងឆ្នាំប្រតិទិនតែមួយ ។

**ប្រាក់ជំនួយឥតសំណង** : ចំនួនទឹកប្រាក់មូលនិធិមានកំណត់ ដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាលទៅឱ្យអង្គភាពរដ្ឋបាលមូលដ្ឋាន ( ស្រុក ឃុំ/សង្កាត់ និងខេត្ត/ក្រុង) យោងទៅតាមវិសមភាពសារពើពន្ធដែលបានវាស់វែង ។ សិទ្ធិនេះអាចត្រូវបានទាមទារដោយអង្គភាពមូលដ្ឋានទាំងនោះ ដែលមានសមត្ថភាពសារពើពន្ធក្រោមមធ្យម គឺអង្គភាពដែលចំណូលផ្ទាល់របស់ពួកគេមិនអាចបង្គ្រប់ការចំណាយបាន។

**ពន្ធដោយប្រយោល** : ពន្ធលើទំនិញ និងសេវា ដែលត្រូវបានប្រមូលដោយប្រយោលតាមរយៈភ្នាក់ងារ ដូចជា អ្នកនាំចូល អ្នកផលិត ឬហាង ឧទាហរណ៍ គឺពន្ធលើអាករបន្ថែមរដ្ឋាករ ពន្ធគយ ពន្ធលើផលរបរ ។

**ឥណទានចំណាយ**: ពាក្យដែលត្រូវបានប្រើនៅក្នុងច្បាប់ថវិកាជាតិកម្ពុជា អធិប្បាយអំពីថវិកាអនុម័តដែលរំពឹងទុកពីម្ចាស់ជំនួយ ។ មិនមែនគ្រប់កម្មវិធីវិនិយោគ (ឥណទានជាប់សន្យា) ដែលបានស្នើសុំសុទ្ធតែត្រូវបានរំពឹងថា នឹងត្រូវបានអនុម័តទាំងអស់ទេ ។

**ឥណទានកម្មវិធី** : ពាក្យដែលត្រូវបានប្រើនៅក្នុងច្បាប់ថវិកាជាតិកម្ពុជា អធិប្បាយអំពីថវិកាសរុបសំរាប់ការវិនិយោគមូលធន ( ផ្តល់មូលនិធិដោយប្រភពក្នុងស្រុក និងប្រភពខាងក្រៅ) ។

**បំណុលសាធារណៈ** : ការជំពាក់បំណុលសរុបរបស់ប្រទេសមួយដែលជំពាក់ឥណទាយកក្នុងប្រទេស ឬបរទេសនៅក្នុងពេលជាក់លាក់ណាមួយ ។នេះគឺជាឱនភាពដែលកើនឡើងក្នុងថវិកាគ្រប់កម្រិត ដែលក្នុងនោះរដ្ឋប្រមូល និងចំណាយធនធាន ( ថវិកាជាតិ ថវិការបស់អង្គភាពមូលដ្ឋាន ថវិការបស់មូលនិធិថវិកាបន្ថែម) ។

**ផ្នែកសាធារណៈ** : នេះគឺជាផ្នែកនៃសេដ្ឋកិច្ចជាតិ ដែលតាមន័យទូលំទូលាយបំផុតគ្របដណ្តប់លើគ្រប់កម្រិតនៃរដ្ឋាភិបាល ប្រព័ន្ធសុខុមាលភាព និងសាជីវកម្មសាធារណៈ ។

**ចំណូល** : លុយដែលត្រូវបានប្រមូលដោយរដ្ឋ ។ នេះរាប់បញ្ចូលទាំងពន្ធ ថ្លៃឈ្នួល និងថ្លៃសេវាផ្សេងៗ និងប្រាក់ចំណូលពីការលក់ទ្រព្យមូលធនដែលគ្រប់គ្រងដោយរដ្ឋ ។

**អតិរេក** : ចំនួនលើសនៃចំណូលលើចំណាយនៅក្នុងរយៈពេលជាក់លាក់ណាមួយ ។

**ពន្ធ** : ចំណូលសាធារណៈមួយប្រភេទដែលត្រូវបានបង្ហាញជាការចំណាយដោយបង្ខំទៅឱ្យរដ្ឋដោយគ្មានអត្ថប្រយោជន៍តបវិញណាមួយ ។

**រតនាគារ** : ប្រព័ន្ធនៃការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុលើចំណូលចំណាយ និងបំណុលសាធារណៈរបស់រដ្ឋាភិបាល ។ នេះរាប់បញ្ចូលទាំងការធ្វើផែនការ ការប្រតិបត្តិ ការអភិបាល និងការប្រើប្រាស់ធនធាននៃថវិកា ។

ឧបសម្ព័ន្ធ ២

# ឯកសារសម្រាប់អានបន្ថែម និងគេហទំព័រដែលពាក់ព័ន្ធ និងមានប្រយោជន៍

## ឯកសារសម្រាប់អានបន្ថែម[១០]

### ១. ឯកសារច្បាប់ថវិកា (ចាប់ពីឆ្នាំ១៩៩៩ មក)

ច្បាប់ថវិកា បង្ហាញអំពីការព្យាករណ៍អំពីចំណូល និងចំណូល/ចំណាយដែលបានស្នើសម្រាប់ឆ្នាំសារពើពន្ធថ្មី និងនិន្នាការនៃចំណាយមូលធនសម្រាប់រយៈពេលពីរឆ្នាំក្រោយ ។ ច្បាប់នេះក៏បង្ហាញពីការចំណាយ និងចំណូល នៅក្នុងឆ្នាំសារពើពន្ធមុនផងដែរ ។ ច្បាប់ថវិកាជាទូទៅគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ នៅដើមឆ្នាំ សារពើពន្ធថ្មី (ខែមករា) នៅបណ្ណាល័យជាតិ រឺបណ្ណាល័យសភាជាតិ និងព្រឹទ្ធសភា។

### ២. ឯកសារច្បាប់ស្តីពីការទូទាត់ថវិកា (១៩៩៧-២០០៤)

ច្បាប់ស្តីពីការទូទាត់ថវិកា ពន្យល់ពីទិដ្ឋភាពទូទៅអំពីការចំណាយដែលត្រូវបានកំណត់ក្នុងថវិកា (ដូចដែលមានចែងក្នុងច្បាប់ថវិកា) និងធ្វើការប្រៀបធៀបជាមួយចំណាយពិត ។ ច្បាប់នេះ ក៏ផ្តល់បន្ថែមនូវព័ត៌មាន អំពីមូលនិធិបន្ថែម ដែលបានចំណាយនៅក្នុងឆ្នាំសារពើពន្ធណាមួយ ។ គួរកត់សំគាល់ផងដែរថា ច្បាប់ស្តីពីការទូទាត់ថវិកា មិនបានបញ្ជាក់ឱ្យបានច្បាស់អំពីរបៀបដែលលុយត្រូវបានចំណាយ និងលទ្ធផលដែលទទួលបានទេ។ ទោះជាច្បាប់ស្តីពីការទូទាត់ថវិកា ជាទូទៅគួរត្រូវបានរៀបចំ និងផ្សព្វផ្សាយដល់សាធារណជនប្រាំបួនខែបន្ទាប់ពីឆ្នាំសារពើពន្ធចាស់ បច្ចុប្បន្ននេះមិនទាន់មានការអនុវត្តន៏បែបនេះឡើយ ។ ខណៈពេលដែលសៀវភៅណែនាំនេះកំពុងត្រូវបានចងក្រង ច្បាប់ស្តីពីការទូទាត់ថវិកា មានការយឺតយ៉ាវរហូតដល់បីឆ្នាំ ។ ដូចច្បាប់ថវិកាជាតិដែរ ច្បាប់ទូទាត់ថវិកានេះមាននៅបណ្ណាល័យជាតិ រឺបណ្ណាល័យសភាជាតិ និងព្រឹទ្ធសភា។

[១០] *ឯកសារទាំងនេះ បច្ចុប្បន្នភាព នាពេលអនាគត មាននៅគម្រោងតាមដានថវិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (សូមមើលអាសយដ្ឋានទាក់ទងដែលមាននៅខាងចុងសៀវភៅណែនាំនេះ) ។*

## ៣. ការវិភាគច្បាប់ថវិកាឆ្នាំ២០០៧

ការវិភាគនេះពិនិត្យលើគម្រោងចំណាយរបស់រដ្ឋាភិបាលនិងធ្វើការប្រៀបធៀបចំណាយនេះជាមួយនឹងការចំណាយក្នុងច្បាប់ថវិការឆ្នាំមុនៗ ព្រមទាំងធ្វើការពិនិត្យទៅលើការចំណាយទៅលើវិស័យអាទិភាពវិស័យមិនមែនអាទិភាព ។ ការវិភាគច្បាប់ថវិកាឆ្នាំ ២០០៧ ត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីឃ្លាំមើលការអភិវឌ្ឍ(ឆ្នាំទី៣ លេខ១) កម្ពុជា ដែលអាចរកបានតាមគេហទំព័រ http://www.ngoforum.org.kh/Development/Docs/doc.htm.

## ៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាអាចរកបានក្នុងបណ្ណាល័យដែលលើកឡើងក្នុងលេខ ១ និង២ ក៏ដូចជាតាមគេហទំព័រ http://www.cambodia.gov.kh.

## ៥. ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាអាចរកបានក្នុងបណ្ណាល័យដែលលើកឡើងក្នុងលេខ ១ និង២ ក៏ដូចជានៅអាជ្ញាធរសវនកម្មជាតិ ។

## ៦. ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាអាចរកបានក្នុងបណ្ណាល័យដែលលើកឡើងក្នុងលេខ ១ និង២ ។

## ៧. ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិកម្ពុជា (NSDP) ឆ្នាំ២០០៦-២០១០

ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិគឺឯកសារតែមួយ ជាឯកសារគោលណែនាំ និងជាឯកសារយោង និងជា "ប្លង់សម្រាប់ការរីកចម្រើនទៅមុខ" (សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន) ។រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ខាងក្រៅត្រូវគោរពតាមយ៉ាងម៉ឺងម៉ាត់ទៅនឹងអាទិភាពដែលបានចែងនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិនេះ ។ ផែនការនេះដោនលូតបានតាមវេបសាយរបស់ក្រសួងផែនការ ដែលមានគេហទំព័រ http://www.mop.gov.kh/.

# គេហទំព័រដែលពាក់ព័ន្ធ និងមានប្រយោជន៍

## ១. វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

www.ngoforum.org.kh

ផ្នែកបញ្ហាអភិវឌ្ឍន៍ មានឯកសារស្តីពីការអភិវឌ្ឍបច្ចុប្បន្នភាពផ្សេងៗ ដូចជាឯកសារគោលជំហរដាក់ជូនវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលដាក់ជូនកិច្ចប្រជុំ CDCF និងទស្សនាវដ្តីឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា ដែលមានអត្ថបទស្តីពីថវិកា និងបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍផ្សេងទៀត ។

## ២. វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

www.eicambodia.org

ផ្នែកបោះពុម្ពផ្សាយរបស់វិទ្យាស្ថានសេដ្ឋកិច្ច ផ្តល់នូវឯកសារភាគច្រើនដែលទាក់ទងនឹងសេដ្ឋកិច្ច រាប់បញ្ចូលទាំងអត្ថបទស្តីពីថវិកាផងដែរ ។

## ៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

http://www.mef.gov.kh/

ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែ ដោយនាយកដ្ឋានសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្សព្វផ្សាយដល់សាធារណជននូវព័ត៌មានស្ថិតិស្តីពីបញ្ហាសេដ្ឋកិច្ចផ្សេងៗ ។ ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ អាចរកបានជាភាសាខ្មែរ និងភាសាអង់គ្លេស ។ អ្នកអាន អាចមើលឯកសារនេះជាភាសាទាំងពីរនៅពេលតែមួយនៅក្នុងទម្រង់ PDF (PDF format) ។

## ៤. គម្រោងថវិកាអន្តរជាតិ (IBP)

http://www.internationalbudget.org/

គម្រោងថវិកាអន្តរជាតិ មានធនធានមួយចំនួនដែលអាចជួយដល់ក្រុមមនុស្សរៀនបានច្រើនអំពីការងារថវិកាអនុវត្តន៍ និងទាក់ទងជាមួយក្រុមការងារថវិកាសង្គមស៊ីវិល នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលឆ្លងកាត់សម័យអន្តរកាល ។ ធនធានទាំងនេះរួមមាន បណ្ណាល័យដ៏ទូលំទូលាយ ព័ត៌មាន និងអាសយដ្ឋានទាក់ទងសម្រាប់មនុស្សជាច្រើននៃក្រុមការងារថវិកា ដែលគម្រោងថវិកាអន្តរជាតិធ្វើការជាមួយ ផ្នែកធនធានដ៏ទូលំទូលាយ និងព័ត៌មានអំពីព្រឹត្តិការណ៍អន្តរជាតិរបស់គម្រោងថវិកាអន្តរជាតិ ។គម្រោងថវិកាអន្តរជាតិក៏បោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មានរៀងរាល់ពីរខែម្តងផងដែរ ។

## ៥. សៀវភៅណែនាំសម្រាប់ការងារថវិកាសម្រាប់អង្គការមិនមែនរដ្ឋាភិបាល

http://www.internationalbudget.org/resources/guide/index.htm

សៀវភៅណែនាំអំពីការងារថវិកា គឺជាសៀវភៅណែនាំដែលបានបង្កើតឡើងមុនសៀវភៅណែនាំស្តីពី ការងារលើប្រាក់ចំណូលនេះ ។ សៀវភៅនេះ ផ្តល់នូវព័ត៌មានអំពីគោលការណ៍ និងការអនុវត្តនៃការងារថវិកាអនុវត្ត និងបញ្ជីធនធានដ៏ទូលំទូលាយសម្រាប់ព័ត៌មានបន្ថែម ។

## ៦. ករណីសិក្សាអំពីក្រុមថវិកាដ៏រឹងមាំប្រាំមួយ

http://www.internationalbudget.org/casestudies.htm

គម្រោងថវិកាអន្តរជាតិនិងវិទ្យាស្ថានសម្រាប់ការសិក្សាពីការអភិវឌ្ឍ បានធ្វើការសិក្សាដ៏ទូលំទូលាយមួយលើផលប៉ះពាល់នៃការងារថវិកាអនុវត្តនៅក្នុងប្រទេសចំនួនប្រាំមួយ : ប្រេស៊ីល ក្រូអាត ឥណ្ឌា ម៉ិចស៊ិកូ អាហ្វ្រិកខាងត្បូង និងអ៊ូហ្កាន់ដា ។ ការសិក្សានោះសន្និដ្ឋានថា ក្រុមថវិកានៅក្នុងប្រទេសទាំងនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងលើផ្នែកមួយចំនួន រាប់បញ្ចូលទាំងការលើកកំពស់តម្លាភាពថវិកា ការបង្កើនធនធានសម្រាប់កម្មវិធីគាំទ្រជនក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ធនធានទាំងនេះ ។

## ៧. កម្រងសំណួរបើកចំហថវិកា

